N°11
23.3.02

# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២០-៣-២០០២ | - ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៧៣ ស្តីពីការតែងតាំង ឯកឧត្តម **ជួង ខែម** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើរដ្ឋមន្ត្រី | ៦២៧ |
| ២០-៣-២០០២ | - ព្រះរាជក្រឹត្យ នស/រកត/០៣០២/០៧៤ ស្តីពីការផ្តល់សញ្ជាតិតាមសញ្ជាតូបនីយកម្ម ដល់លោក **លីន យុនហាន** ( LIN YUN HAN ) សញ្ជាតិដើមចិន | ៦២៨ |


## I- ក្រុមប្រឹក្សាធម្មនុញ្ញ


| | | |
|---|---|---|
| ១៩-៣-២០០២ | -សេចក្តីជូនដំណឹងលេខ ០១/២០០២ កបធ.សជណ | ៦២៨ |


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ១៨-៣-២០០២ | -អនុក្រឹត្យលេខ ១៩ អនក្រ ប.ក ស្តីពីការបង្កើតអង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ | ៦៣០ |
| ២០-៣-២០០២ | -អនុក្រឹត្យលេខ ២០ អនក្រ ប.ក ស្តីពីការដាក់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅជាអង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ | ៦៣៣ |
| ២០-៣-២០០២ | -អនុក្រឹត្យលេខ ២១ អនក្រ ប.ក ស្តីពីការប្រគល់ភារកិច្ចជូនអាជ្ញាធរ ខេត្តសៀមរាបថែរក្សានិងគ្រប់គ្រង" **សណ្ឋាគារទីឡាអង្គរ**" | ៦៣៥ |
| ១៨-៣-២០០២ | -អនុក្រឹត្យលេខ ១២៨ អនក្រ ត.ត ស្តីពីការជូនមេដាយការងារ | ៦៣៧ |
| ១៨-៣-២០០២ | -អនុក្រឹត្យលេខ ១២៩ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៦៤០ |
| ១៨-៣-២០០២ | -អនុក្រឹត្យលេខ ១៣០អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៦៤១ |
| ១៨-៣-២០០២ | -អនុក្រឹត្យលេខ ១៣១ អនក្រ តត ស្តីពីការជូនមេដាយសហមេត្រី | ៦៤២ |
| ១៩-៣-២០០២ | -អនុក្រឹត្យលេខ ១៣២ អនក្រ តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៤៣ |
| ១៩-៣-២០០២ | -អនុក្រឹត្យលេខ ១៣៣ អនក្រ តត ស្តីពីការតែងតាំងទីប្រឹក្សា | ៦៤៤ |
| ២១-៣-២០០២ | -អនុក្រឹត្យលេខ ១៣៤ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៦៤៥ |
| ២១-៣-២០០២ | -អនុក្រឹត្យលេខ ១៣៥ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៦៤៧ |
| ២១-៣-២០០២ | -អនុក្រឹត្យលេខ ១៣៦ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៦៤៨ |
| ២១-៣-២០០២ | -អនុក្រឹត្យលេខ ១៣៧ អនក្រ តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៤៩ |

២១-៣-២០០២ -អនុក្រឹត្យលេខ ១៣៨ អនក្រ តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៥០

២១-៣-២០០២ -អនុក្រឹត្យលេខ ១៣៩ អនក្រ តតស្តីពីការតែងតាំងមន្ត្រីរាជការ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ៦៥១

## ២. សេចក្តីសំរេច

១៩-៣-២០០២ -សេចក្តីសំរេចលេខ ១៩ សសរ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអាហារូបករណ៍ នៃមូលនិធិព្រះអាទិត្យ ៦៥៤

២០-៣-២០០២ -សេចក្តីសំរេចលេខ ២០ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះ សំរាប់សិក្សានិងវាយតំលៃ លើកំពែងស្តារនិងកិវឌ្ឍន៍រមណីយដ្ឋាន តំបន់ ប្រាសាទបន្ទាយផ្ការ-ប្រាសាទបន្ទាយទ័ព- ប្រាសាទឯកភ្នំ និង ប្រាសាទភ្នំបាណន់សំរាប់បំរើសំណូមពរនិងវិនិយោគរបស់ក្រុមហ៊ុន SOKHA-HOTEL Co,LTD ៦៥៦

### ៣.សារាចរណែនាំ

២១-៣-២០០២ - សារាចរណែនាំលេខ ០៤ សរណន ស្តីពីការរៀបចំទិវាវប្បធម៌ជាតិ ៣ មេសា លើកទី៤ នៃព្រះរាជាណាចក្រកម្ពុជា ៦៥៩

## III- ការងារបណ្តាក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១៥-៣-២០០២ -ប្រកាសអន្តរក្រសួងលេខ ២៣២ សហវ ស្តីពីការតែងតាំងរដ្ឋលេខាធិការរងរបស់... ប្រទានទៅក្រសួងមហាផ្ទៃ( អាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀន ) ៦៦៣

១៥-៣-២០០២ -ប្រកាសអន្តរក្រសួងលេខ ២៣៣ សហវ ស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទានទៅលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៦៦៥

១៥-៣-២០០២ -ប្រកាសអន្តរក្រសួងលេខ ២៣៤ សហវ ស្តីពីការបង្កើតរដ្ឋទេយ្យករបុរេ ប្រទាននៅលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៦៦៧

១៥-៣-២០០២ -ប្រកាសអន្តរក្រសួងលេខ ២៣៥ សហវ ស្តីពីការតែងតាំងភ្នាក់ងារបើក ផ្តល់សំរាប់បើកប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការនៅស្នងការនគរបាលខេត្តពោធិសាត់ ៦៦៩

### ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

១៨-៣-២០០២ -ប្រកាសលេខ ៧៨ បទ.ប្រក ស្តីអំពីសេវាជួលជាវបរិបថទូរគមនាគមន៍អក្ខរៈលេខ (Digital Leased Capacity ) ៦៧១

១៨-៣-២០០២ -ប្រកាសលេខ៧៩ បទ.ប្រក ស្តីអំពីសេវាស្ថាបនាការថែទាំទូរស័ព្ទ ទូរសារ និង

ទូរពុម្ពក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង ៦៧៩

១៨-៣-២០០២ -ប្រកាសលេខ ៨០បទ.ប្រក ស្ដីអំពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ ៦៨៤

១៨-៣-២០០២ -ប្រកាសលេខ ៨១ បទ.ប្រក ស្ដីពីថ្លៃសេវាទូរគមនាគមន៍និងរូបភាព ទូរទស្សន៍ប្រើប្រាស់ក្នុងប្រទេសនិងអន្តរជាតិ ៦៩៦


### ៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា


១៨-៣-២០០២ -ប្រកាសលេខ ២៦៣ អយក.ប្រក ស្ដីពីការបើកសាលាបឋមសិក្សាឯកជនខ្មែរ-ចិន ពួយ ហ្វា ៧០៤

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៧៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ជួន ខែម** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

**មាត្រា ២:** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០២*

*៣.រ.ល-០២.០៣.០០៨៣*

លេខ : ៦៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០២/០៧៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លីន យុនហាន** ( LIN YUN-HAN ) សញ្ជាតិដើមចិន កើតថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៥២ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៧៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

(ហត្ថលេខា និង ត្រា)

[illegible] តាន់

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០២

៣៣៤.០២.០៣.០០៧៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០១/២០០២ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០២

## សូមជំរាបមក

## ឯកឧត្តម លោកជំទាវ ជាអ្នកតំណាងរាស្ត្រចំនួន ១៤រូប

**កម្មវត្ថុ** : ករណីបណ្តឹងពីការបំពានរដ្ឋធម្មនុញ្ញមាត្រា៥១ថ្មី មាត្រា៥០ មាត្រា៣៥ មាត្រា៣៦ និងមាត្រា១២២ថ្មី របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងសំដីដែលថ្លែងនៅកិច្ចប្រជុំវេទិកាការដ្ឋាភិបាល និងឯកជន កាលពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០២ ។

**យោង** : លិខិតចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០២ របស់ឯកឧត្តម លោកជំទាវ

តបតាមសេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលបណ្តឹងរបស់ឯកឧត្តម លោកជំទាវរួចហើយ ហើយបានរួមប្រជុំពិនិត្យខ្លឹមសារដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនោះនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០២ ។

ក្រោយពីបានពិនិត្យយ៉ាងហ្មត់ចត់នូវបទបញ្ញត្តិទាំងឡាយនៃរដ្ឋធម្មនុញ្ញ និងព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨/០៤/៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ អង្គប្រជុំក្រុមប្រឹក្សា-ធម្មនុញ្ញយល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចពិនិត្យធម្មនុញ្ញភាពនៃច្បាប់ និងសេចក្តីសំរេចនានារបស់ស្ថាប័នរដ្ឋតែក្នុងក្របខ័ណ្ឌនៃមាត្រា១៤០ថ្មី មាត្រា១៤១ថ្មី មាត្រា១៥០ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា១៧ មាត្រា១៨ និងមាត្រា១៩ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨/០៤/៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញប៉ុណ្ណោះ ។ ពាក្យសំដីរបស់សម្តេចនាយករដ្ឋមន្ត្រី មិនទាន់ក្លាយជាសេចក្តីសំរេចរដ្ឋបាលក្នុងរូបភាពណាមួយនៅឡើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញសូមបញ្ជាក់ម្យ៉ាងទៀតថា ការត្រួតពិនិត្យធម្មនុញ្ញភាពនៃសេចក្តីសំរេចរបស់ស្ថាប័ននានានឹងអាចធ្វើទៅបានតែក្នុងក្របខ័ណ្ឌនៃនីតិវិធីដែលមានចែងក្នុងមាត្រា១៩ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨/០៤/៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញតែប៉ុណ្ណោះ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានការសោកស្តាយដោយពុំមានលទ្ធភាពបំពេញបំណងតាមពាក្យបណ្តឹងរបស់ឯឧត្តម លោកជំទាវបាន ក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមានសព្វថ្ងៃ ។

សូមឯកឧត្តម លោកជំទាវ ទទួលនូវសេចក្តីរាប់អានដោយស្មោះអំពីខ្ញុំ ។៚

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៩ អនក្រ. បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតអង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់

✧

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

### ស ម្រេ ច

**មាត្រា ១.-**

បង្កើតអង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់មួយ ក្រោមការគ្រប់គ្រងនៃអគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ២.-**

អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ ជាសេនាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពកំណែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ដែលមានជាអាទិ៍÷

- ការកសាងច្បាប់តាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- ការចូលរួមរៀបចំការងារ ពង្រឹងសមត្ថភាព កសាងច្បាប់ នៅតាមស្ថាប័នរដ្ឋ និងតាមរយៈសិក្ខាសាលា
- ការតាមដានត្រួតពិនិត្យ និងជំរុញការងារកសាងច្បាប់ តាំងពីដើមទីរហូតដល់ការប្រកាសឱ្យប្រើ
- ការសម្របសម្រួលនៅកម្រិតការផ្តួចផ្តើមកសាងច្បាប់ រវាងអង្គភាព ក្រសួង ស្ថាប័ន និងអង្គការអន្តរជាតិ ឬប្រទេសអ្នកផ្តល់ជំនួយក្នុងវិស័យកំណែទម្រង់ច្បាប់
- ការបង្ក និងរៀបចំឱ្យមានការចូលរួមផ្តល់យោបល់ពីអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលនានា
- ការសម្រួល និងពិនិត្យឡើងវិញនូវទម្រង់ ការបកប្រែ ឃ្លោងឃ្លា និងការប្រើពាក្យពេចន៍ នៃសេចក្តីព្រាងចុងក្រោយ
- ការផ្សព្វផ្សាយច្បាប់ និងវិធានសំខាន់ៗជាទូទៅក្នុងទូទាំងប្រទេស រួមមានការរៀបចំ និងចែកចាយរាជកិច្ច ព្រមទាំងឯកសារពាក់ព័ន្ធផ្លូវការចាំបាច់ទាំងឡាយ
- ការងាររដ្ឋបាល និងហិរញ្ញកិច្ចរបស់អង្គភាព
- ការអនុវត្តរាល់ភារកិច្ច ដែលប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលប្រគល់ឱ្យ ។

**មាត្រា ៣.-**

អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ មានការិយាល័យរដ្ឋបាល និងហិរញ្ញកិច្ចមួយ ដើម្បីបម្រើកិច្ចដំណើរការរបស់ខ្លួន ។ ការិយាល័យរដ្ឋបាល និងហិរញ្ញកិច្ចនេះ ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាលកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៤.-**

សមាសភាព នៃអង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ ត្រូវជ្រើសរើសក្នុងចំណោមសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃរាជរដ្ឋាភិបាល ។ អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ អាចស្នើសុំប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ឱ្យអញ្ជើញអ្នកច្បាប់ពីបណ្តាអង្គភាពឯកជននានា ស្ថាប័ន និងពីអង្គការក្រៅរដ្ឋាភិបាល មកបំពេញការងារជាអ្នកជំនាញការឱ្យអង្គភាពនេះ ។

**មាត្រា ៥.-**

អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនអគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្នុងករណីពិសេស ជូនប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៦.-**

អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ មានសមាសភាពដូចតទៅ :

ឯកឧត្តម **សំ សុខផល** ជាប្រធាន

ឯកឧត្តម **ឡេង ប៉េងឡុង** អនុប្រធាន

ឯកឧត្តម **ក្រាញ់ ជ័យលាភីនូនី** សមាជិក

ឯកឧត្តម **ស៊ុយ ម៉ុងលាង** សមាជិក

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា ៦ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី***

***"ដើម្បីសុំហត្ថលេខា"***

**ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការដាក់ទីចាត់ការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអង្គភាពអនុវត្តថវិកាឧបសម្ព័ន្ធ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១. នស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង មានការប្រែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ/បក/ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ. បក. ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃថវិកាឧបសម្ព័ន្ធ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ. បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុងស្វយ័តរាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ. បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ដាក់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានតួនាទី និង ភារកិច្ច ដូចមានចែងក្នុងជំពូកទី ១៩ មាត្រាទី ២១ នៃអនុក្រឹត្យ លេខ ០៤ អនក្រ. បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ជាអង្គភាពអនុវត្តន៍ថវិកាឧបសម្ព័ន្ធ ។

**មាត្រា២:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធផ្តល់សេវាបណ្តុះបណ្តាលរយៈពេលខ្លី រយៈពេលមធ្យមនូវជំនាញពាក់ព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងថ្នាក់បរិញ្ញាប័ត្រ និង បរិញ្ញាប័ត្រជាន់ខ្ពស់ តាមរូបភាពបង់ថ្លៃ ។

**មាត្រា៣:** អង្គភាពនេះ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យលេខ ៧០ អនក្រ. បក ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃថវិកាឧបសម្ព័ន្ធ ។

**មាត្រា៤:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និង ហិរញ្ញវត្ថុនៃរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៥:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំគំរោងចំណូល- ចំណាយថវិកាឧបសម្ព័ន្ធប្រចាំឆ្នាំ អោយបានត្រឹមត្រូវ និង ទាន់ពេលវេលា ដើម្បីបញ្ចូលក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។

**មាត្រា៦:** វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំនូវរបាយការណ៍ចំណូល- ចំណាយថវិកាឧបសម្ព័ន្ធប្រចាំត្រីមាសជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយបានទាន់ពេលវេលា និងនៅបំណាច់ឆ្នាំត្រូវបិទបញ្ជីបូកសរុបការទូទាត់ចំណូល- ចំណាយ ដើម្បីបញ្ចូលទៅក្នុងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗ ។

**មាត្រា៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ - កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនអាជ្ញាធរខេត្តសៀមរាប ថែរក្សា និងគ្រប់គ្រង "សណ្ឋាគារវីឡាអប្សរា"

៚✳៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បទបញ្ជាលេខ ៣០/បប ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រាជរដ្ឋាភិបាល

-អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបដិសេធមិនទទួលស្គាល់សិទ្ធិរបស់តំណាងសាលាខេត្តសៀមរាប ក្នុងការងារចុះកិច្ចសន្យាជួលសណ្ឋាគារវីឡាអប្សរា

-តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**មាត្រា១ :** -កែសំរួលខ្លឹមសារមាត្រា៣ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០០ ទៅជា "ប្រគល់សិទ្ធិជូនអាជ្ញាធរខេត្តសៀមរាប ថែរក្សា និងគ្រប់គ្រងសណ្ឋាគារវីឡាអប្សរា លើផ្ទៃដីចំនួន ៥.៧៩៧ ម៉ែត្រក្រឡា ដើម្បីបំរើទិសដៅស្តារ និងអភិវឌ្ឍន៍ ដោយផ្អែកតាមច្បាប់ និងបទបញ្ញត្តិជាធរមាន" ។

-ក្រៅពីនេះ មាត្រាដទៃទៀតត្រូវរក្សាទុកខ្លឹមសារដដែល ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប និងគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ០៣ ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១២៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន ៥៧ រូប នៃក្រសួងធម្មការ និងសាសនា ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ជូនក្រសួងក្នុងឆ្នាំ ២០០១ ដូចមានរាយនាម ខាងក្រោមនេះ ÷

**ក_មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-លោក | **សេខ** | **ណាត** | អគ្គនាយករងធម្មការ |
| ២-លោក | **ស្វាយ** | **ហ៊ាខ** | ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ |
| ៣-លោក | **តាន់** | **សុខន** | ប្រធាននាយកដ្ឋានធម្មការ |
| ៤-លោក | **ត្រេស** | **សារ៉ុម** | អធិការនៃអធិការដ្ឋាន |
| ៥-លោក | **ខួន** | **វ៉ាន់ចន្ទី** | ប្រធាននាយកដ្ឋាន ពុទ្ធសាសនបណ្ឌិត្យ |
| ៦-លោក | **ម៉ែន** | **ប្រាជ្ញ** | ប្រធាននាយកដ្ឋាន អប់រំផ្សព្វផ្សាយ |
| ៧-លោកស្រី | **យឹម** | **យុជាវណ្ណ** | ប្រធាននាយកដ្ឋាន ពាហិរសាសនា |

**ខ. មេដាយប្រាក់ការងារ :**

| | | | |
|---|---|---|---|
| ១-លោក | អ៊ួច | សុភារ័ន្ធ | អនុប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ |
| ២-លោក | ខុន | តារា | អនុប្រធាននាយកដ្ឋាន ពាហិរសោសនា |
| ៣-លោកស្រី | ផុន | ផល្លា | អធិការរង |
| ៤-លោក | អ៊ុច | សួរ | អនុប្រធាននាយកដ្ឋាន អប់រំផ្សព្វផ្សាយ |
| ៥-លោក | អ៊ុម | ឈាន់ | អនុប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ |
| ៦-លោក | ស៊ុប | វ៉ែស់ម៉ាខ | អនុប្រធាននាយកដ្ឋាន ពាហិៈសាសនា |
| ៧-លោក | គីម | ប៊ូរ៉ា | អនុប្រធាននាយកដ្ឋាន អប់រំផ្សព្វផ្សាយ |
| ៨-លោកស្រី | ឃិន | ចំរើន | អនុប្រធាននាយកដ្ឋាន ពុទ្ធសាសនបណ្ឌិត្យ |

**គ. មេដាយសំរិទ្ធការងារ :**

| | | | |
|---|---|---|---|
| ១-លោក | ហ៊ុច | យ៉ាន | ប្រធានការិ.ពុទ្ធិកមហាវិទ្យាល័យ |
| ២-លោក | ខៀវ | បញ្ញាវុឌ្ឍ | នាយករងពុទ្ធសាសនបណ្ឌិត្យ |
| ៣-លោកស្រី | សម | យ៉ុន | ប្រធានការិយាល័យ |
| ៤-លោក | ម៉ុច | សារេន | ប្រធានការិយាល័យរដ្ឋបាល និង នីតិកម្ម |
| ៥-លោក | អ៊ុច | វណ្ណៈ | ប្រធានការិយាល័យពុទ្ធិកវិទ្យាល័យ |
| ៦-លោក | យស់ | ឈាង | ប្រធានការិយាល័យធម្មវិន័យ |
| ៧-លោកស្រី | ស្រី | ស៊ីលីម | ប្រធានការិយាល័យធម្មការ |
| ៨-លោកស្រី | ហោ | ផល្លីន | ប្រធានការិយាល័យ |
| ៩-លោកស្រី | ហ៊ុយ | គន្ធា | ប្រធានការិយាល័យ |
| ១០-លោកស្រី | កែវ | សុធារី | ប្រធានការិយាល័យបុគ្គលិក |
| ១១-លោក | ឆើម | ឆាត | អនុប្រធានការិយាល័យ |
| ១២-លោក | គីម | តារា | ប្រធានការិយាល័យ |
| ១៣-លោក | ស៊ុន | ឈាន់ | ប្រធានការិយាល័យពាហិរសាសនា |
| ១៤- លោក | ព្រុំ | អ៊ុន | ប្រធានការិយាល័យពុទ្ធិកបឋមសិក្សា |
| ១៥-លោក | មឿង | យ៉ុន | អនុប្រធានការិយាល័យ |
| ១៦-លោក | ស៊ឹម | យុន | អនុប្រធានការិយាល័យ |
| ១៧-លោក | ខៀវ | រ៉ាឌី | អនុប្រធានការិយាល័យពុទ្ធិកសិក្សា |
| ១៨- លោក | ឌិន | ម៉េងសែ | ប្រធានការិយាល័យអធិការកិច្ច |
| ១៩- លោក | សុខ | ហួរ | ប្រធានការិយាល័យ |
| ២០-លោក | តាំ | ដាំផេង | អនុប្រធានការិយាល័យ |

| | | | |
|---|---|---|---|
| ២១-លោក | យ៉ឹន | សុវណ្ណ | មន្ត្រីការិយាល័យផែនការគណនេយ្យ |
| ២២-លោក | យក់ | គន់ | មន្ត្រីជំនាញអប់រំ-ធម្មទេសនា |
| ២៣-លោក | សំ | គិន | មន្ត្រីការិយាល័យរដ្ឋបាល |
| ២៤- លោក | ផាន់ | យ៉ាង | មន្ត្រីការិយាល័យរដ្ឋបាល |
| ២៥-លោក | កែម | សុមន៍ | មន្ត្រីការិយាល័យពុទ្ធិកមហាវិទ្យាល័យ |
| ២៦-លោក | ខោត | កុសល | មន្ត្រីការិយាល័យពុទ្ធិកបឋមសិក្សា |
| ២៧-លោក | សុខ | ចាន់ | មន្ត្រីពុទ្ធសាសនបណ្ឌិត្យ |
| ២៨-លោក | ហ៊ុន | សេដា | មន្ត្រីការិយាល័យរដ្ឋបាល |
| ២៩-លោក | ម៉ុង | នី | មន្ត្រីពុទ្ធិកឧត្តមសិក្សា |
| ៣០- លោក | ដា | ចំរើន | មន្ត្រីអធិការកិច្ច |
| ៣១-លោក | កៅ | ឆឿន | មន្ត្រីនាយកដ្ឋានពាហិរសាសនា |
| ៣២-លោក | លាត | លីហាន | មន្ត្រីការិយាល័យគ្រប់គ្រងសម្ភារៈបរិក្ខារ |
| ៣៣-កញ្ញា | ញ៉ៀម | គីមហុង | មន្ត្រីការិយាល័យបុគ្គលិក |
| ៣៤- លោក | ផុក | តារិន | មន្ត្រីអធិការដ្ឋានពុទ្ធិកសិក្សា |
| ៣៥- លោក | ជួង | សីន | មន្ត្រីអធិការដ្ឋានពុទ្ធិកសិក្សា |
| ៣៦-លោក | ពៅ | ស៊ុម | អនុប្រធានការិយាល័យ |
| ៣៧-លោក | ឡុច | ណារ៉ា | អនុប្រធានការិយាល័យ |
| ៣៨-លោក | ពិ | ប៊ុន្នីន | អនុប្រធានការិយាល័យ |
| ៣៩-កញ្ញា | គ្រួច | គន្ធា | មន្ត្រីពុទ្ធិកសិក្សា |
| ៤០-លោកស្រី | អឿន | សម្បត្តិ | មន្ត្រីខុទ្ទកាល័យ |
| ៤១-លោកស្រី | ដា | ប៊ុនយ៉ឹង | អនុប្រធានការិយាល័យ |
| ៤២-លោកស្រី | ហាំម៉ាត់ | អាស៊ីយ៉ា | មន្ត្រីពិធីការ |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១២៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ០៤ រូប ដែលបានបរិច្ចាគថវិកា ដើម្បីជួយកសាងសមិទ្ធផលនានា ស្ថិតនៅក្នុងវត្តអង្គរំដួល វត្តព្រៃចំណា ឃុំខ្សែត្រ និង វត្តព្រៃម្នាស់ ឃុំសំឡី ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដូចមាននាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោកជំទាវ **លី គីម** ថវិកា ១៤.៦៧៤ USD

២-លោក **សេក សៀន** ថវិកា ១១.០៨៥ USD

៣-លោក **សុខ ឆាន** ថវិកា ១០.០១៣ USD

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

-លោកយាយ **យិន សាន** ថវិកា ៣.៧៧០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ២ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៣០ អនក្រ.តក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៣ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងវិហារឥស្លាម នៅក្នុងភូមិវាលក្លោក ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមនេះ ÷

**ក_មេដាយមាសស្ថាបនាជាតិ**

-លោក **ហាជី អូស្មាន អះម៉ាត់** នៅប្រទេសម៉ាឡេស៊ី ថវិកាចំនួន ១០.០០០ USD

**ខ_មេដាយប្រាក់ស្ថាបនាជាតិ**

១-លោក **យូណុះ អាពូប៉ាកា** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.៦០០ USD

២- **ហាគីម តួននិងសមាជិកចំណុះវិហារ** ថវិកាចំនួន ៥.៥០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...១៧១...អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក Gorm Jeppesen ប្រធានទីប្រឹក្សាបច្ចេកទេស គំរោងគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរសមុទ្រ ដែលមានស្នាដៃល្អ ក្នុងការជួយរៀបចំការងារគ្រប់គ្រងបរិស្ថាន តំបន់ឆ្នេរសមុទ្រកម្ពុជា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ៣ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣២ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ NS/ KRT - 34 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងព្រះបរមរាជវាំង
- យោងលិខិតលេខ ១២៤ .មស.គត ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០០២ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងលិខិតលេខ ១០០ / ០២ វរ. លស ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០០២ របស់ក្រសួងព្រះបរមរាជវាំង

## សំរេច

**មាត្រា ១ :** តែងតាំងមន្ត្រីរាជការក្រសួងព្រះបរមរាជវាំង ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

១ - លោក ឡាក់ គី អនុប្រធាននាយកដ្ឋាន ទំនាក់ទំនង ជាជំនួយការឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

២ - លោក ផេង ភិរុណ អនុប្រធាននាយកដ្ឋាន រដ្ឋបាល ជាជំនួយការឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

៣ - លោក វ៉ាន់ វ៉ាន អនុប្រធាននាយកដ្ឋាន ពិធីការ ជាជំនួយការឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

៤ - កញ្ញា សូ គន្ធកុសល អនុប្រធាននាយកដ្ឋាន សំណង់ ជាជំនួយការឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ,រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ,រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ , សហរដ្ឋមន្ត្រី , រដ្ឋមន្ត្រី , រដ្ឋលេខាធិការ , គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣៣ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងទីប្រឹក្សា

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំ រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំង ឯកឧត្តម អ៊ីស្សេ អ៊ីណូអេ ( ISSEI INOUE ) អតីតរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជប៉ុន ជាទីប្រឹក្សារបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកការងារបណ្តុះបណ្តាលធនធានមនុស្ស ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី/រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៣៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ធំ

## ស ំ រេ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន ០១ និងសប្បុរសជន ០២ រូប ដែលបានចំណាយថវិកាជួយកសាងសមិទ្ធផលនានា នៅក្នុងខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោមនេះ ៖

១ - ក្រុមហ៊ុន **មូហ៊ីបា** (MUHIBAHH) ជួយកសាងសួនច្បារ ០១ កន្លែង នៅទីរួមខេត្តកំពង់ធំ ចំណាយអស់ទឹកប្រាក់ចំនួន ១៥.៣០០ USD

២ - ឯកឧត្តម **តាគី អ៊ីតូណាកាតា** (TAKIHITONAKATA) ឯកអគ្គរាជទូតកិត្តិយស នៃអ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ជួយកសាងមណ្ឌលសុខភាព០១ ខ្នង និងបំពាក់សង្ហារឹមគ្រប់គ្រាន់ នៅភូមិអាត់ស៊ូ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ចំណាយអស់ទឹកប្រាក់ចំនួន ១០.៧០០ USD

៣ - លោក **នូ សុផាន់** ជួយកសាងផ្លូវលំមួយខ្សែ ប្រវែង ៨០០ ម៉ែត្រ លូទឹក ០១ និងបំពាក់បង្គោលភ្លើង ខ្សែភ្លើង និង អគ្គិសនី នៅភូមិស្វាកែត ឃុំព្រៃតាហ៊ូ ស្រុកស្ទឹងសែន ចំណាយអស់ទឹកប្រាក់ចំនួន ១០.៥០០ USD

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនខ្មែរ ០៣ រូប រស់នៅទីក្រុងឡុងប៊ិច រដ្ឋ កាលីហ្វូញ៉ា សហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងស្ពានបេតុងមួយកន្លែង ប្រវែង ២៥ ម៉ែត្រ ទទឹង ០៥ ម៉ែត្រ នៅចំណុចព្រែកស្ពានដែក ភូមិស្ពានដែក ឃុំព្រែកទន្លាប់ ស្រុកលើកដែក ខេត្តកណ្តាល ដូចមាននាមខាងក្រោម ÷

**ក‸មេដាយមាសស្ថាបនាជាតិ :**

-អ្នកស្រី **សេក សារឿនគន** ទឹកប្រាក់ ៣០.០០០ USD

**ខ‸មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **សេក សុជាតិ** ទឹកប្រាក់ ៦.០០០ USD

២-លោក **ឈ្មើ អ៊ុំ** ទឹកប្រាក់ ៦.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/៚

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៣ រូប ដែលបានបរិច្ចាគធនធានជួយកសាងសមិទ្ធផលសាធារណៈនានា និង ជួយប្រជាពលរដ្ឋរងគ្រោះ នៅស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដូចមាននាមខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-លោក | **ជួន** | **គុល** | បរិច្ចាគទឹកប្រាក់ ១៣៩.៦៣៩ USD |
| ២-លោក | **ឡាយ** | **ស៊ា** | បរិច្ចាគទឹកប្រាក់ ១៣៣.៦២៥ USD |
| ៣-លោកជំទាវ | **ហេង** | **ហ៊ាច** | បរិច្ចាគទឹកប្រាក់ ៣៧.៥០០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

III,KSP.Appointment

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ឡុង គែម** បច្ចុប្បន្នប្រធាននាយកដ្ឋានអាស៊ីទី១ អោយទទួលភារកិច្ចថ្មី ជាប្រធាននាយកដ្ឋានរដ្ឋបាល នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី/ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

III.KSP.Appointment

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៨ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំង លោក **ហែម សាងម** អតីតអគ្គកុងស៊ុល នៃស្ថានអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហូជីមិញ ជាប្រធាននាយកដ្ឋានអាស៊ីទី១ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជំនួសលោក **ឡុង គែម** ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ/បក/ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨៩/ អនក្រ/បក/ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

**សម្រេច**

**មាត្រា១:** ត្រូវបានតែងតាំងមន្ត្រីរាជការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម:

១- លោក **ថៅ ចេដ្ឋា** ជាជំនួយការឯកឧត្តម សុខ ចិន្តា សមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើអគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- លោក **ស៊ឹន ចាន់ស៊ីរីវុត្ថា** ជាជំនួយការឯកឧត្តម វង្សី វិស្សុត សមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិមានឋានៈ ស្មើអគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- លោក ទៅ **ស៊ីម សុរិយា** ជាជំនួយការឯកឧត្តម វង្សី វិស្សុត សមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិមានឋានៈ ស្មើអគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

៤- លោក **ជុំ សំណាង** ជាជំនួយការឯកឧត្តម ឈៀង យ៉ាណោរ៉ា សមាជិកនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិមានឋានៈ ស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មិនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនចំពោះសប្បុរសជន ០៣ ក្រុម ដែលបានផ្តល់ថវិកាជួយកសាងអាគារសិក្សា ៦០ ខ្នង នៅខេត្តកំពង់ស្ពឺ និង ខេត្តព្រៃវែង ក្នុងតំរោងទឹកប្រាក់ ២.៦លានដុល្លារអាមេរិក ដូចមានខាងក្រោមនេះ ÷

១- **Aeon Group**

២- **Miyake Co.Ltd**

៣- **Japan Committee for UNICEF**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួង អប់រំ យុវជននិង កីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៩.សសរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិ
## អាហារូបករណ៍ នៃមូលនិធិព្រះអាទិត្យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មាធិការជាតិអាហារូបករណ៍ នៃមូលនិធិព្រះអាទិត្យ ដែលមានសមាសភាពដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | សម្តេច | ហ៊ុន សែន | នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា | ប្រធានកិត្តិយស |
| ២- | ឯកឧត្តម | សុខ អាន | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ៣- | ឯកឧត្តម | អ៊ឹម សិទ្ធី | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | អនុប្រធាន |
| ៤- | ឯកឧត្តម | ស៊ាន បូរ៉ាត | ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា | អនុប្រធាន |
| ៥- | បណ្ឌិត | ជា វ៉ាន់ដេត | ទីប្រឹក្សាឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អគ្គលេខាធិការ |
| ៦- | ឯកឧត្តម | ពេជ សោភ័ន | អគ្គនាយកឧត្តមសិក្សា បច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ៧- | លោក | ជា អឿន | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងអប់រំយុវជននិងកីឡា | សមាជិក |
| ៨- | លោក | ឃឹម ពិសិដ្ឋ | ប្រធាននាយកដ្ឋានអប់រំ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- | លោក | ច្រឹង លឹមស្រ៊ី | ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅនៃក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ១០- | អ្នកស្រី | ភាន្ទ នារី | អនុប្រធាននាយកដ្ឋានទំនាក់ទំនងវប្បធម៌ និង អាហារូបករណ៍ នៃក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |

41

**ប្រការ ២:** គណៈកម្មាធិការជាតិនេះ មានភារកិច្ចទទួលខុសត្រូវ និង គ្រប់គ្រងមូលនិធិព្រះអាទិត្យអោយមានតម្លាភាព ។

**ប្រការ ៣:** គណៈកម្មាធិការជាតិនេះ មានភារកិច្ចជ្រើសរើសសិស្សពូកែជំរើសជាតិ ផ្នែកអក្សរសិល្ប៍, គណិតវិទ្យា និងរូបវិទ្យា ដើម្បីបញ្ជូនអោយទៅសិក្សាបន្តនៅប្រទេសជប៉ុន ចាប់ពីឆ្នាំសិក្សា២០០១-២០០២ នេះតទៅ ។

**ប្រការ ៤:** ដើម្បីរៀបចំការងារនេះអោយបានល្អ និង មានភាពរលូននោះ គណៈកម្មាធិការជាតិនេះ ត្រូវសហការ និងទំនាក់ទំនងជាមួយភាគីជប៉ុនដែលជាម្ចាស់អំណោយ ជាប្រចាំ ព្រមទាំងធ្វើការអំពាវនាវដល់សប្បុរសជនកម្ពុជា អោយចូលរួមជាវិភាគទានក្នុងមូលនិធិព្រះអាទិត្យអោយបានកាន់តែច្រើន ដើម្បីជាគុណប្រយោជន៍ដល់កូនខ្មែរ ។

**ប្រការ ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តនូវសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣០ ស.ស.រ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការចំរុះ
## សំរាប់សិក្សា និងវាយតំលៃលើគំរោងវិនិយោគស្តារ និងអភិវឌ្ឍន៍
## រមណីយដ្ឋានតំបន់ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយធំ ប្រាសាទឯកភ្នំ
## និងប្រាសាទភ្នំបាណន់ សំរាប់បំរើសំណូមពរវិនិយោគ
## របស់ក្រុមហ៊ុន SOKHA HOTEL CO., LTD.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទិ ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

- យោងស្មារតីអង្គប្រជុំ"ច្រកចេញ-ចូលតែមួយ" នៃក.អ.ក"គ.វ.ក" នាថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០២
- តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ១:** បង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សា និងវាយតំលៃលើគំរោងវិនិយោគស្ពារ និងអភិវឌ្ឍន៍រមណីយដ្ឋាន តំបន់ប្រាសាទបន្ទាយឆ្មារ-ប្រាសាទបន្ទាយទ័ព ក្នុងខេត្តបន្ទាយមានជ័យ និងប្រាសាទឯកភ្នំ-ប្រាសាទភ្នំបាណន់ ក្នុងខេត្តបាត់ដំបង សំរាប់បំរើសំណូមពរវិនិយោគរបស់ក្រុមហ៊ុន **SOKHA HOTEL CO., LTD.** ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ឌី យ៉ាវ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- | ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តម **ជុច តឿន** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- | ឯកឧត្តម **ឈន អៀម** | រដ្ឋលេខាធិការ ក្រសួងធម្មការ និងកិច្ចការសាសនា | សមាជិក |
| ៥- | ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦- | ឯកឧត្តម **សួន សិទ្ធី** | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ៧- | ឯកឧត្តម **រស់ រ៉េន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨- | ឯកឧត្តម **ប្រាជ្ញ ស៊ុន** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៩- | ឯកឧត្តម **សេង លឹមនៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០- | ឯកឧត្តម **ថាច់ ឃន** | អភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ១១- | ឯកឧត្តម **ប្រាជ្ញ ចន្ទ** | អភិបាលខេត្តបាត់ដំបង | សមាជិក |
| ១២- | ឯកឧត្តម **ខេព ហែន** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១៣- | លោក **មុខ ប៊ុនហួន** | ប្រធាននាយកដ្ឋាន ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

សមាជិកគណៈកម្មការទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** គណៈកម្មការនេះ មានភារកិច្ចដូចតទៅ :

ក- ចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែងនូវបញ្ហាចំពោះមុខបច្ចុប្បន្ន អំពីផលដែលអាចនាំអោយមានការប្រែប្រួលបរិស្ថាន នៅតំបន់ប្រាសាទបន្ទាយឆ្មារ - ប្រាសាទបន្ទាយទ័ព - ប្រាសាទភ្នំបាណន់ និងប្រាសាទឯកភ្នំ ។

ខ- សិក្សា និងវាយតំលៃលើទិដ្ឋភាពច្បាប់-បច្ចេកទេសពាក់ព័ន្ធដល់គំរោងវិនិយោគស្ពារ និងអភិវឌ្ឍន៍រមណីយដ្ឋានទាំង០៤ខាងលើ ដូចមានចែងក្នុងប្រការ១ ដើម្បីធ្វើជាមូលដ្ឋានសំរាប់ការពិនិត្យសំរេចក្នុងអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" លើសំណើសុំវិនិយោគរបស់ក្រុមហ៊ុន **SOKHA HOTEL CO., LTD.** នេះ នាពេលខាងមុខម្តងទៀត ។

ក្នុងករណីសំណើសុំវិនិយោគរបស់ក្រុមហ៊ុននេះ ត្រូវបានអនុញ្ញាតអោយវិនិយោគដោយមានការលើកទឹកចិត្តនោះ គណៈកម្មការនេះត្រូវមានភារកិច្ចបន្ត ដូចខាងក្រោម :

- រៀបចំបែបបទ ឯកសារគតិយុត្តិ - កំណត់ផែនការសកម្មភាព ព្រមទាំងរៀបចំប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ធម្មជាតិវប្បធម៌ទាំង០៤កន្លែង "តំបន់ប្រាសាទបន្ទាយឆ្មារ-ប្រាសាទបន្ទាយទ័ព - ប្រាសាទភ្នំបាណន់ និងប្រាសាទឯកភ្នំ" អោយបានច្បាស់លាស់ ដើម្បីធានាការគ្រប់គ្រង និងថែរក្សាតំបន់ប្រាសាទអោយបានល្អតាមលំនាំនៃព្រះរាជក្រឹត្យ ស្តីពីការបង្កើតរមណីយដ្ឋានភ្នំព្រះរាជទ្រព្យកន្លងមក
- តាមដានជាប្រចាំ នូវរាល់ការអនុវត្តការងាររបស់ក្រុមហ៊ុន តាមជំហាននីមួយៗ
- លើកសំណើសុំការសំរេចពីរាជរដ្ឋាភិបាល ចំពោះករណីដែលហួសពីសមត្ថកិច្ចរបស់ខ្លួន
- រាយការណ៍អំពីលទ្ធផលការងារជាបន្តបន្ទាប់ជូនរាជរដ្ឋាភិបាល ។

**ប្រការ៣:** គណៈកម្មការនេះ មានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី- សហរដ្ឋមន្ត្រីក្រសួងក្រសួងមហាផ្ទៃ- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ- រដ្ឋមន្ត្រីក្រសួងទេសចរណ៍- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់- រដ្ឋមន្ត្រីក្រសួងបរិស្ថាន- រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា- ប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា- រដ្ឋមន្ត្រីគ្រប់ក្រសួង- ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ...០៤...ស.រ.ណ.ន

# សារាចរណែនាំ

## ស្តីពីការរៀបចំទិវាវប្បធម៌ជាតិ ៣ មេសា
## លើកទី ៤ នៃព្រះរាជាណាចក្រកម្ពុជា

អនុវត្តតាមស្មារតីអនុក្រឹត្យលេខ ២៤ អនក្រ.បកចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើត " **ទិវាវប្បធម៌ជាតិ** " រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី ០៣ មេសា រៀងរាល់ឆ្នាំ ធ្វើជា " **ទិវាវប្បធម៌ជាតិ** " នៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងស្ថានភាពដែលពិភពលោកកំពុងអនុវត្តនយោបាយសកលភាវូបនីយកម្ម នៅឆ្នាំ២០០២នេះ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានផ្សេងៗក្នុងវិស័យវប្បធម៌ ដើម្បីធានាឱ្យមានតម្លាភាពនិងប្រែក្លាយបាតុភូតសកលភាវូបនីយកម្ម ឱ្យទៅជាកំលាំងវិជ្ជមាន សំរាប់ការលើកតម្កើង និងអភិវឌ្ឍន៍វប្បធម៌ជាតិ ដែលនឹងធ្វើឱ្យមានការទទួលស្គាល់និងផ្តល់តម្លៃជាអន្តរជាតិ នូវមរតកវប្បធម៌ជាតិកម្ពុជាបន្ថែមទៀត ។ ក្នុងន័យនេះដែរ ដើម្បីអនុវត្តគោលដៅចំបងទាំងបីរបស់រាជរដ្ឋាភិបាល គឺ :

-ការកាត់បន្ថយភាពក្រីក្រ

-ការអភិវឌ្ឍសង្គមប្រកបដោយចីរភាព

-ការកសាងសមធម៌ និងយុត្តិធម៌សង្គម ។

ក្នុងការរៀបចំទិវាវប្បធម៌ជាតិ ០៣ មេសា លើកទី៤ ឆ្នាំ ២០០២ នេះ រាជរដ្ឋាភិបាលបានសំរេចកំណត់លើកយកប្រធានបទដែលមានខ្លឹមសារ " **អភិរក្ស និង អភិវឌ្ឍវប្បធម៌ដើម្បីសមធម៌សង្គម** " ក្នុងគោលបំណង :

-រៀបចំតំបន់មានប្រាសាទបុរាណនានា ឱ្យទៅជារមណីយដ្ឋានទេសចរណ៍វប្បធម៌

-ជំរុញវិស័យឯកជនក្នុងការផលិតនូវផលិតផលវិស័យវប្បធម៌ ត្រឹមត្រូវតាមក្បួនខ្នាតជាតិ សំរាប់បំរើទីផ្សារក្នុងស្រុក និងអន្តរជាតិ

-បង្កើនការផ្សាយវប្បធម៌ខ្មែរតាមគ្រប់រូបភាព ពិសេសតាមវិទ្យុ ទូរទស្សន៍ សារពត៌មាន និងអ៊ីនធឺណែត

-ដាស់ព្រលឹងខ្មែរគ្រប់រូបឱ្យក្រោកឡើងព្រមៗគ្នា ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ បញ្ចេញ សកម្មភាពរួមគ្នាជាឯកច្ឆ័ន្ទ និងជាបន្ទាន់ ក្នុងការធ្វើឱ្យមានតម្លៃ និងថែរក្សាវប្បធម៌ជាតិ ឱ្យបានគង់វង្ស ប្រកបដោយលក្ខណៈចរិតជាតិចំរើនរុងរឿងថ្កុំថ្កើង ថ្លៃថ្នូរ និងអនាគត ភ្លឺស្វាង សំរាប់មនុស្សជំនាន់ក្រោយ ។

ដើម្បីឱ្យការរៀបចំពិធីទិវាវប្បធម៌ជាតិ ០៣ មេសានេះ ប្រព្រឹត្តទៅបានល្អប្រសើរ រាជរដ្ឋាភិបាលសូមធ្វើ ការណែនាំ ដូចតទៅ :

១-គ្រប់ក្រសួងស្ថាប័ន អាជ្ញាធរខេត្តក្រុង គ្រប់វត្តអារាម គ្រឹះស្ថានសាធារណៈ ប្រពន្ធ័ឃោសនា ក្រុមហ៊ុនឯកជន អង្គការ សមាគមនានា ត្រូវ :

-អបអរសាទរទិវាវប្បធម៌ជាតិ ព្រមទាំងបំផុស និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ត្រីរាជការ នគរបាល កងទ័ពគ្រប់ប្រភេទ សិស្ស និស្សិត ព្រះសង្ឃ ប្រជាពលរដ្ឋគ្រប់ស្រទាប់ឱ្យយល់ដឹងអំពីនយោបាយ វប្បធម៌ជាតិ អត្តសញ្ញាណជាតិ ស្មារតីការពារថែរក្សាវប្បធម៌ជាតិ សិល្បៈបេតិកភណ្ឌវប្បធម៌ជាតិ និងស្លៀកពាក់ តាមទំនៀមទំលាប់ប្រពៃណីដ៏ល្អ របស់ជាតិយើង

-បំផុសឱ្យគ្រប់ក្រសួង ស្ថាប័ន អាគារសាធារណៈ ទីប្រជុំជន វត្តអារាម បូជណីយដ្ឋាន ព្រះវិហារ សាលារៀន លើកទង់ជាតិ ទង់ផ្កាលា និងបដាអបអរសាទរ

-បំផុសឱ្យធ្វើការតុបតែងលំអ និងបំភ្លឺភ្លើងឱ្យបានភ្លឺព្រោងព្រាតនៅរាជធានីភ្នំពេញ គ្រប់ខេត្ត ក្រុង ខណ្ឌ ស្រុក ឃុំសង្កាត់ ទីប្រជុំជន វត្តអារាម ។

២-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវ :

-ចងក្រងអត្ថបទ ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ អំពីនយោបាយវប្បធម៌ ស្មារតីការពារវប្បធម៌ សិល្បៈ បេតិកភណ្ឌវប្បធម៌ជាតិ ទំនៀមទំលាប់ប្រពៃណីដ៏ល្អប្រពៃរបស់ជាតិ និងស្មារតីគោរពច្បាប់ និងបទ ប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រង និងការការពារវប្បធម៌ជាតិ និងបរិស្ថានជាតិ

- សហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ និងស្ថាប័នពាក់ពន្ធ័រៀបចំទិវា វប្បធម៌ជាតិនៅថ្ងៃទី ០៣ មេសា នៅរាជធានីភ្នំពេញ ឱ្យបានទទួលលទ្ធផលល្អប្រសើរ

- ណែនាំមន្ត្រីវប្បធម៌និងវិចិត្រសិល្បៈខេត្ត-ក្រុងសហការជាមួយអាជ្ញាធរដែនដីផ្សព្វផ្សាយអត្ថបទ ខាង លើនេះ ឱ្យបានជ្រួតជ្រាបដល់ មូលដ្ឋាន និងសំដែងសិល្បៈជូនប្រជារាស្ត្រទស្សនាកំសាន្ត តាមទីសាធារណៈ ព្រមទាំងបំផុសចលនាប្រជាពលរដ្ឋ ចូលរួមចាត់ចែងពិធីផ្សារណាត់លក់ផលិតផលវប្បធម៌ លេងល្បែងប្រជាប្រិយ របស់ជាតិ រាំកំសាន្តនៅតាមកន្លែង ដែលមានប្រាសាទបុរាណ រមណីយដ្ឋាន វត្តអារាម ទីប្រជុំជន តាមទំនៀម ទំលាប់ របស់តំបន់នីមួយៗ

- ធ្វើការជ្រើសរើសវរៈសិល្បករ សិល្បការិនីមានស្នាដៃឆ្នើមប្រចាំឆ្នាំ និងអញ្ជើញវរៈសិល្បករ សិល្បការិនីចាស់ ដែលបានជ្រើសរើសជារៀងរាល់ឆ្នាំ តាំងពីឆ្នាំ១៩៩៣ មកជួបសំណេះសំណាលដើម្បីលើកទឹកចិត្ត ។

៣-ក្រសួងពត៌មានរៀបចំផ្សព្វផ្សាយខ្លឹមសារ ឯកសារ និងបណ្តាសកម្មភាពវប្បធម៌សំខាន់ៗ ដែលបំរើឱ្យទិវាវប្បធម៌ជាតិ ០៣ មេសា តាមរយៈប្រពន្ធ័ឃោសនាជាតិ ពិសេសវិទ្យុ ទូរទស្សន៍ជាតិ វិទ្យុ ទូរទស្សន៍ឯកជន និងសារពត៌មាន តាមការពិភាក្សា ជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

៤-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើការណែនាំដល់ស្ថានតំណាងកម្ពុជានៅបរទេស ជួយបង្កលក្ខណៈនិងបំផុសស្មារតីដល់ប្រជាជន សហគមន៍ខ្មែរនៅបរទេសគ្រប់មជ្ឈដ្ឋានដើម្បីចូលរួមក្នុងទិវាវប្បធម៌ជាតិ ០៣ មេសា ក្នុងន័យថែរក្សាការពារអត្តសញ្ញាណជាតិ ។

៥-ក្រសួងធម្មការ និងសាសនា ត្រូវនិមន្តព្រះសង្ឃ ក្រសួងអប់រំយុវជននិងកីឡា ចាត់តាំងមន្ត្រី សិស្សនិស្សិត ក្រសួងទេសចរណ៍ អញ្ជើញក្រុមហ៊ុនទេសចរណ៍ ឱ្យចូលរួមធ្វើពលកម្មថែរក្សាបោសសំអាតប្រាង្គ ប្រាសាទ និងវត្តអារាម ដែលមានក្នុងមូលដ្ឋានរបស់ខ្លួន ឱ្យបានផុលផុសល្អប្រសើរ ជាពិសេសត្រូវបំផុសឱ្យសរសេរកំណាព្យ គូរគំនូរបំរើឱ្យខ្លឹមសារ " **អភិរក្ស និងអភិវឌ្ឍវប្បធម៌ដើម្បីសមធម៌សង្គម** " ។

៦-ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវមានផែនការណែនាំដល់គ្រប់ខេត្តក្រុង និងអង្គភាពក្រោមឱវាទ បង្កើនកិច្ចការពារបេតិកភណ្ឌជាតិជាប្រចាំ និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ បង្កឱ្យការរៀបចំទិវាវប្បធម៌ជាតិ ០៣ មេសា បានសំរេចភារកិច្ច ប្រកបដោយក្តីសប្បាយរីករាយ និងសុវត្ថិភាពបរិបូរណ៍ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តតាមខ្លឹមសារខាងលើនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី..២១..ខែ..[illegible]..ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នខេត្តក្រុង

-ឯកសារ "កាលប្បវត្តិ"

# ពាក្យស្លោក " ទិវាវប្បធម៌ជាតិ ៣ មេសា "

១. ជយោ ! ព្រះរាជាណាចក្រកម្ពុជា

២. ជយោ ! សម្តេចឪព្រះបិតាវប្បធម៌ជាតិ

៣. អបអរសាទរ " ទិវាវប្បធម៌ជាតិ ០៣ មេសា " លើកទី ៤ ឆ្នាំ ២០០២

៤. ជយោ ! វប្បធម៌សន្តិភាព

៥. ជាតិរស់ព្រោះវប្បធម៌គង់វង្ស

៦. វប្បធម៌រលំជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កុំថ្កើង

៧. វប្បធម៌ជាគ្រឹះ នៃការអភិវឌ្ឍសង្គម

៨. វប្បធម៌ជាដួងព្រលឹងរបស់ជាតិ

៩. លើកតំកើងវប្បធម៌ជាតិ គឺលើកតំលៃខ្លួនឯង

១០. អភិវឌ្ឍន៍សង្គមវប្បធម៌សន្តិភាព ជាភារកិច្ចរបស់ខ្មែរគ្រប់រូប

១១. បាត់បង់វប្បធម៌ គឺបាត់បង់អត្តសញ្ញាណជាតិ

១២. អភិរក្ស និងអភិវឌ្ឍវប្បធម៌ ដើម្បីសមធម៌សង្គម

១៣. ជយោ ! វប្បធម៌ខ្មែរអមតៈ

១៤. ជយោ ! សម្តេចឪ សម្តេចម៉ែ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៣២ សហវ.......

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងវេជ្ជបណ្ឌិតប្រចាំការ នៅក្រសួងមហាផ្ទៃ

## ( អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន )

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស-រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស ៩៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស / រកម / ១២៩៩ / ១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស.រកម / ១២០១/ ១៥.ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណ

នៃយស្សាធារណៈ

- បានឃើញសារាចរណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តិទៅនៃរដ្ឋទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន ។

## សំរេច

**ប្រការ១ :** ត្រូវបានតែងតាំងលោក **លី គីមឡុង** ឋានៈ ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជារដ្ឋទេយ្យករបុរេប្រទាន និង លោក **លឹម នាង** ប្រធានការិយាល័យគណនេយ្យស្តីទី នៃនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ជារដ្ឋទេយ្យករបុរេប្រទានជំនួស នៅអមក្រសួងមហាផ្ទៃ ( អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន )

**ប្រការ២ :** សេចក្តីសំរេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣ :** អគ្គលេខាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានធនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ ក្រោមឱវាទ ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ( អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ) ព្រមទាំងលោក **លី គីមឡុង** និង លោក **លឹម នាង** មានភារកិច្ច ទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង  យូ ហុកគ្រី

<u>កន្លែងទទួល :</u>

- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាប "
- ដូចប្រការ ៣ " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៣៣ សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងជំនួយការបុរេប្រទាន
## នៅលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២. ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែ ប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២

-បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទ បញ្ញត្តទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការអនុវត្តន៍បទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញសារាចរណែនាំលេខ ០០៣ ស.ហ.វ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រព្រឹត្តិទៅនៃវគ្គគណនេយ្យបុរេប្រទាន

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន

## សំរេច

**ប្រការ១** : ត្រូវបានតែងតាំងជារដ្ឋទេយ្យករបុរេប្រទាននៅអមលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដូចខាងក្រោម :

-លោក **សំ ប្រជាមានិត** ឋានៈជា ប្រធានការិយាល័យគណនេយ្យ ជារដ្ឋទេយ្យករបុរេប្រទាន ។

-កញ្ញា **ឡៀល ម៉ូរី** ឋានៈជា មន្ត្រីការិយាល័យគណនេយ្យ ជារដ្ឋទេយ្យករបុរេប្រទានជំនួស ។

**ប្រការ២** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទាំងអស់ និង លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ព្រមទាំង លោក សំ ប្រជាមានិត និង កញ្ញា ឡៀល ម៉ូរី ត្រូវទទួលបន្ទុក អនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

លេខាធិការ
នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

**ឡៀល មុន**

ចម្លងជូន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ២

"ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៣៣៤ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតវគ្គទេយ្យបុរេប្រទាន
## នៅលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២. ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែ ប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២

-បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទ បញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញសារាចរណែនាំលេខ ០០៣ ស.ហ.វ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីវគ្គទេយ្យបុរេប្រទាន

-បានឃើញប្រកាសលេខ១២៩ ប្រក.សហវ ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ១៩៩៧ ស្តីពីការកំនត់ទឹកប្រាក់រដ្ឋទេយ្យបុរេប្រទានជំពូក១១ សំរាប់ទូទាត់ចំណាយចាំបាច់ ទៅលើដំណើរការរដ្ឋបាលសំភារៈ និង ថ្លៃសំពុលតូច ។

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន

## សំរេច

**ប្រការ១** :ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទានជំពូក១១ នៅលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដើម្បី ទូទាត់ចំណាយទាំងឡាយណាដែលមានចែងក្នុងមាត្រា៦៤នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ។ ចំនួនទឹកប្រាក់ជាអតិបរិមា នៃការចំណាយដែលអនុញ្ញាត អោយរដ្ឋទេយ្យករបុរេប្រទាន ធ្វើការទូទាត់ត្រូវ កំណត់កំរិតក្រោម ៥០០.០០០,០០ (ប្រាំរយពាន់រៀលគត់) តាមចំណាត់ថ្នាក់ចំណាយនីមួយៗ ដូចមានចែងក្នុងតារាង ឧបសម្ព័ន្ធ ភ្ជាប់ជាមួយប្រកាសអន្តរក្រសួង ។

**ប្រការ២** :ចំនួនទឹកប្រាក់ នៃរដ្ឋទេយ្យបុរេប្រទាន ជំពូក១១ សំរាប់មួយជុំនៃឆ្នាំ ត្រូវបានកំណត់ត្រឹម ចំនួន ១០.៥០០.០០០,០០ (ដប់លានប្រាំរយពាន់រៀលគត់) ។

**ប្រការ៣** :អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ត្រូវទទួលបន្ទុក អនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

អគ្គលេខាធិការ
នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

**ទៀល មុន**

<u>ចម្លងជូន</u>

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចប្រការ៣
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៣៣៩ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០២

# ប្រកាសអន្តរក្រសួង

## ស្តី ពី

## ការតែងតាំងភ្នាក់ងារបើកផ្តល់ សំរាប់បើកប្រាក់បៀវត្ស និង ប្រាក់អត្ថាគមន៍ ក្នុងវិស័យ សង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ នៅស្នងការដ្ឋាននគរបាលខេត្ត ពោធិ៍សាត់

**- ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**- សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ០២.នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- បានឃើញព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ១១ នស /៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម /១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ .
- បានឃើញព្រះក្រមលេខ នស / រកម / ១២០១ / ១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ .
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ .
- បានឃើញប្រកាសលេខ ០០៤ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ .
- បានឃើញលិខិត ១១៥ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ .
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បច្ចុប្បន្ន .
- បានឃើញសំណើសុំប្តូរ និង រក្សាការតែងតាំងភ្នាក់ងារបើកផ្តល់ និង ភ្នាក់ងារបើកផ្តល់រង ស្នងការដ្ឋាននគរបាលខេត្តក្រុង

## សំរេច

ប្រការ១: -ប្រាក់បៀវត្សរ៍ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ របស់មន្ត្រីរាជការ នៃស្នងការដ្ឋាននគរបាលខេត្ត ពោធិ៍សាត់ នឹងត្រូវបើកផ្តល់តាមរយ: ( ភ្នាក់ងារបើកផ្តល់ )

ប្រការ២: -លោក ខឹម . សុខុម ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ នៅស្នងការដ្ឋាននគរបាល ខេត្ត ពោធិ៍សាត់

-លោក ញ៉ៀម.ណារ័ត្ន ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ជំនួស

ប្រការ៣: -លោក ខឹម.សុខុម និងលោក ញ៉ៀម.ណារ័ត្ន ត្រូវបានអនុញ្ញាតិឱ្យបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិ ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សរ៍ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ .

ប្រការ៤: -បែបបទនៃការអនុវត្តន៍ បើកផ្តល់បៀវត្សរ៍ នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ

ប្រការ៥: -ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និង មូលនិធិដែលបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ

ប្រការ៦: -សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍

ប្រការ៧: -អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្នងការដ្ឋាននគរបាលខេត្ត ពោធិ៍សាត់ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

**កន្លែងទទួល**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណ:រដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៧

" ដើម្បីមុខការ "

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :..........៧៤..........បទ...ប្រក....

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ មិនា ឆ្នាំ 2002

# ប្រកាស

## ស្តីអំពីសេវាជួលជាវបរិមាណទូរគមនាគមន៍អក្សរលេខ

(Digital Leased Capacity)

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា.
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ៦៦អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ០៥អនក្រ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍និងទូរគមនាគមន៍.
- បានឃើញ សេចក្តីសំរេចលេខ ១៥៤សសរ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រម គ្រប់គ្រងតម្លៃ.
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការផែនការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចុះថ្ងៃទី 04 ខែ មិនា ឆ្នាំ 2002 ស្តីអំពីតម្លៃសេវាទូរគមនាគមន៍ សំរាប់ឆ្នាំ 2002 ដែលរៀបចំស្នើឡើងដោយក្រុមការងារតំណាងអង្គភាពជំនាញ.

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៩១០/៤២៦៥១០
ទូរសារ: (៨៥៥) ២៣-៤២៦៩៩២/៤២៦០១១

## ស ំ រេ ច

**ប្រការ ១** : កំណត់ថ្លៃសេវាផ្តល់ជាវបរិបថទូរគមនាគមន៍អក្ខរៈលេខក្នុងក្រុង រយៈផ្លូវឆ្ងាយក្នុងប្រទេស និងអន្តរជាតិ ដូចមានឧបសម្ព័ន្ធទី 1 ដល់ឧបសម្ព័ន្ធទី 3 ភ្ជាប់ជាមួយនេះ ។

**ប្រការ ២** : រាល់បញ្ញត្តិនៃប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣** : ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និងបណ្តាអង្គភាពក្រុងក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ។

**ប្រការ ៤** : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

សូ ខុន

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៣
  " ដើម្បីអនុវត្តន៍ "
- ឯកសារ-កាលប្បវត្តិ.

ប្រកាសលេខ បទ.ប្រក ចុះថ្ងៃទី ខែ មិនា ឆ្នាំ 2002 ទំព័រ : 1/6

**ឧបសម្ព័ន្ធទី ១**

**ថ្លៃសេវាជួលជាវបរិបថឌីជីថលសមត្ថភាព**

**(tariff of Digital Leased Capacity)**

**ចាប់អនុវត្តន៍ពីថ្ងៃទី 01 ខែ មេសា ឆ្នាំ 2002**

១. **ការប្រើប្រាស់បរិបថអក្ខរៈលេខក្នុងក្រុង** *(Local Lease)* :

បណ្ដាញក្រុងមានស្រាប់ ថ្លៃបង់តាមវេទនាសម្ព័ន្ធ ដូចខាងក្រោម ៖

១.១- ថ្លៃបើកផ្លូវគ្រាដំបូង ចំណុចម្ខាង *(Access Charge/One end)*

១.១.១- ចំណុះល្បឿនរហូត 256Kbps = 125$

១.១.២- ចំណុះល្បឿនរហូត 2,048Kbps = 250$

១.១.៣- ចំណុះល្បឿនស្មើ 8Mbps = 750$

១.២- ថ្លៃជួលជាវប្រចាំខែ តភ្ជាប់ត្រង់ រវាងចំណុចចេញ និងចំណុចចូល ៖

១.២.១- ចំណុះល្បឿន 2.4 ~ 9.6Kbps = 44$

១.២.២- ចំណុះល្បឿន 19.2Kbps = 96$

១.២.៣- ចំណុះល្បឿន 64Kbps = 122$

១.២.៤- ចំណុះល្បឿន 128Kbps = 192$

១.២.៤- ចំណុះល្បឿន 256Kbps = 263$

១.២.៦- ចំណុះល្បឿន 512Kbps = 324$

១.២.៧- ចំណុះល្បឿន 1,024Kbps = 540$

១.២.៨- ចំណុះល្បឿន 1,536Kbps = 720$

១.២.៩- ចំណុះល្បឿន 2,048Kbps = 900$

១.៣- ការស្ថាបនាតប្រគំរវាងទីតាំងប្រើប្រាស់ ជាបន្ទុករបស់អតិថិជន ឬដោយជួលជាវខ្សែ និងបរិបថដោយខ្សែក :

១.៣.១- ថ្លៃជួលជាវខ្សែកាប្លិ៍ *(Leased Line)* រវាងចំណុច *MDF* :

១.៣.១.១- ខ្សែមួយគូ (2W) = 150$/ មួយខែ

១.៣.១.២- ខ្សែពីរគូ (4W) = 225$/ មួយខែ

១.៣.២- ថ្លៃស្ថាបនាខ្សែកាប្លិ៍គិតតាមសារណាការ*(Quotations)* រវាងចំណុច *MDF* :

១.៣.២.១- ខ្សែមួយគូ (2W) គិតអប្បបរិមា = 200$

១.៣.២.២- ខ្សែពីរគូ (4W) គិតអប្បបរិមា = 300$

**២. ការប្រើប្រាស់បរិបថអក្សរលេខរយៈផ្លូវឆ្ងាយក្នុងប្រទេស:**

២.១- ការជួលជាអប្បបរិមា *(Minimum Lease)* ស្មើចំណុះល្បឿន *1xE1* (30 បរិបថទូរស័ព្ទ) និងរយៈពេលមួយឆ្នាំ ។ ចំណុះបរិបថ អាចបានត្រូវផ្គត់ផ្គង់ក្នុងរយៈផ្លូវនៃបណ្តាញ ឬកំណាត់បណ្តាញដោយចេញពីចំណុចម្ខាង ឬចូលទៅចំណុចម្ខាង ឬពីចំណុចមួយ ទៅចំណុចមួយ ។

២.២- ថ្លៃជួលជាបានត្រូវអនុវត្តសរុបតាមរចនាសម្ព័ន្ធដូចខាងក្រោម ៖

២.២.១- ថ្លៃបើកផ្លូវគ្រាដំបូង ចំណុចម្ខាង *(Access Charge/One end)*

២.២.១.១- ចំណុះល្បឿន *1xE1 = 250$*

២.២.១.២- ចំណុះល្បឿន *4xE1 =750$*

២.២.២- ថ្លៃជួលជាប្រចាំខែ *(Monthly Charges)* បានត្រូវអនុវត្តផ្អែកតាមចំណុះល្បឿន ចម្ងាយរយៈផ្លូវមានបី (3)របៀប ៖

២.២.២.១- តប្រគំត្រង់រវាងចំណុចចេញ និងចំណុចចូល :
ថ្លៃត្រូវបង់តាមតារាង MATRIX ដូចខាងក្រោម ។

២.២.២.២- ភ្នំពេញ : តប្រគំដោយប្រើបរិបថ តពន្ធាតជាបណ្តាញក្រុងមានស្រាប់ ថ្លៃបន្ថែម - *450$/E1*

២.២.២.៣- ខេត្ត : តប្រគំដោយប្រើបរិបថតពន្ធាតជាបណ្តាញក្រុងមានស្រាប់ ថ្លៃបន្ថែម - *350$/E1*

២.៣- ការបញ្ចុះថ្លៃលើទឹកប្រាក់សរុបបង់ប្រចាំខែ ៖

២.៣.១- ពី 10,000 ក្រោម 30,000$ បង់ត្រឹម 97%

២.៣.២- ពី 30,000 ក្រោម 50,000$ បង់ត្រឹម 95%

២.៣.៣- ពី 50,000$ ឡើង បង់ត្រឹម 93%

## ៣. ការប្រើប្រាស់បរិបថអន្តរជាតិបណ្ដាញលើដី :

សេវាបានត្រូវផ្តត់ផ្គង់រវាងប្រទេសវៀតណាម និងប្រទេសថៃ ចំពោះក្រុមហ៊ុនការីបណ្តាញទូរគមនាគមន៍ដែលមានអាជ្ញាប័ណ្ណ និងអតិថិជន ដែលមានការអនុញ្ញាតិប្រើប្រាស់ឯកជន ឬ បំរើសាធារណៈ ។

៣.១- បានត្រូវអនុវត្តលក្ខណ្ឌត្រង់ចំណុច ២.១ និងថ្លៃបើកផ្លូវគ្រាដំបូង ត្រង់ចំណុច ២.២ ដូចខាងលើ ។

៣.២- ថ្លៃជួលជាប្រចាំខែ តាមចំណុះល្បឿន និងចម្ងាយរយៈផ្លូវរវាងព្រំប្រទល់ប្រទេស បានត្រូវអនុវត្តតាមតារាង *MATRIX* ដូចឧបសម្ព័ន្ធទី 2 ។

## ៤. ការប្រើប្រាស់បរិបថអន្តរជាតិតាមប្រព័ន្ធស្ថានីយ៍ផ្កាយរណប :

សេវាបានត្រូវផ្គត់ផ្គង់ចំពោះអតិថិជនដែលមានការអនុញ្ញាតិប្រើប្រាស់ឯកជន ឬបំរើសាធារណៈ ។ ថ្លៃប្រើប្រាស់ប្រចាំខែ និងថ្លៃស្ថាបនាគ្រាដំបូងរវាងមជ្ឈមណ្ឌលមាត់ច្រកអន្តរជាតិគិតតាមចំណុះល្បឿន ៖

| | | | |
|---|---|---|---|
| ៤.១- | ចំណុះល្បឿន | 2.4 Kbps = 1,400$/ខែ | ថ្លៃស្ថាបនា = 640$ |
| ៤.២- | ចំណុះល្បឿន | 4.8Kbps = 2,400$/ខែ | ថ្លៃស្ថាបនា = 800$ |
| ៤.៣- | ចំណុះល្បឿន | 9.6 Kbps = 3,100$/ខែ | ថ្លៃស្ថាបនា = 1,040$ |
| ៤.៤- | ចំណុះល្បឿន | 19.2 Kbps = 3,800$/ខែ | ថ្លៃស្ថាបនា = 1,280$ |
| ៤.៥- | ចំណុះល្បឿន | 48 ឬ 56 ឬ 64 Kbps = 5,000$/ខែ | ថ្លៃស្ថាបនា = 1,600$ |
| ៤.៦- | ចំណុះល្បឿន | 128 Kbps = 8,000$/ខែ | ថ្លៃស្ថាបនា = 1,920$ |
| ៤.៧- | ចំណុះល្បឿន | 192 Kbps = 9,900$/ខែ | ថ្លៃស្ថាបនា = 2,240$ |
| ៤.៨- | ចំណុះល្បឿន | 256 Kbps = 12,000$/ខែ | ថ្លៃស្ថាបនា = 2.400$ |
| ៤.៩- | ចំណុះល្បឿន | 384 Kbps = 15,400$/ខែ | ថ្លៃស្ថាបនា = 3,500$ |
| ៤.១០- | ចំណុះល្បឿន | 512 Kbps = 18,000$/ខែ | ថ្លៃស្ថាបនា = 3,500$ |
| ៤.១១- | ចំណុះល្បឿន | 768 Kbps = 23,940$/ខែ | ថ្លៃស្ថាបនា = 3,500$ |
| ៤.១២- | ចំណុះល្បឿន | 1,024 Kbps = 27,000$/ខែ | ថ្លៃស្ថាបនា = 3,500$ |
| ៤.១៣- | ចំណុះល្បឿន | 1,544 Kbps = 33,320$/ខែ | ថ្លៃស្ថាបនា = 3,500$ |
| ៤.១៤- | ចំណុះល្បឿន | 2,048 Kbps = 38,250$/ខែ | ថ្លៃស្ថាបនា = 3,500$ |

# ឧបសម្ព័ន្ធទី ២

## តារាង MATRIX

## ថ្លៃប្រចាំខែ តាមរបៀបគប្រតិប្រង់ រវាងចំណុចចេញ និងចំណុចចូល

(Monthly Lease Between Originating- Terminating Points)

ចាប់អនុវត្តពីថ្ងៃទី 01 ខែ មេសា ឆ្នាំ 2002

ចំណុះល្បឿន 1xE1 គិតជាប្រាក់ដុល្លា មួយខែ (USD)

| | Orig. Term. Points. | Viet nam | Thai land | Bavet | Svay Rieng | Neak Loueng | Phnom Penh | Kg.Ch hnang | Pur sat | Battam bang | Siso phon | Poipet |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 1- | Vietnam | | 10,271 | 5,279 | 5,641 | 6,191 | 6,700 | 7,504 | 8,342 | 9,261 | 9,852 | 10,271 |
| 2- | Thailand | 10,271 | | 10,271 | 9,910 | 9,360 | 8,851 | 8,046 | 7,225 | 6,289 | 5,698 | 5,279 |
| 3- | Bavet | 5,279 | 10,271 | | 1,366 | 1,916 | 2,425 | 3,229 | 4,067 | 4,986 | 5,577 | 5,996 |
| 4- | Svayrieng | 5,641 | 9,910 | 1,366 | | 1,554 | 2,063 | 2,868 | 3,705 | 4,625 | 5,216 | 5,635 |
| 5- | Neakloeung | 6,191 | 9,360 | 1,916 | 1,554 | | 1,513 | 2,318 | 3,155 | 4,075 | 4,666 | 5,085 |
| 6- | P.Penh | 6,700 | 8,851 | 2,425 | 2,063 | 1,513 | | 1,809 | 2,646 | 3,566 | 4,157 | 4,576 |
| 7 | Kg.Chhnang | 7,504 | 8,046 | 3,229 | 2,868 | 2,318 | 1,809 | | 1,842 | 2,761 | 3,352 | 3,771 |
| 8- | Pursat | 8,342 | 7,225 | 4,069 | 3,705 | 3,155 | 2,646 | 1,842 | | 1,924 | 2,515 | 2,934 |
| 9- | Battambang | 9,261 | 6,289 | 4,986 | 4,625 | 4,075 | 3,566 | 2,761 | 1,924 | | 1,595 | 2,014 |
| 10- | Sisophon | 9,852 | 5,698 | 5,577 | 5,216 | 4,666 | 4,157 | 3,352 | 2,515 | 1,595 | | 1,423 |
| 11- | Poipet | 10,271 | 5,279 | 5,996 | 5,635 | 5,085 | 4,576 | 3,771 | 2,934 | 2,014 | 1,423 | |

*កំណត់សំគាល់* : ឥតបានគិតបញ្ចូលថ្លៃអាករ VAT ។

## ឧបសម្ព័ន្ធទី ៣

## អត្ថន័យ និងលក្ខ័ណ្ឌសេវាជួលបរិបថទូរគមនាគមន៍អក្ខរៈលេខ

## (Terms and Conditions of Digital Leased Capacity)

ផ្អែកតាមលទ្ធផលនៃកិច្ចអភិវឌ្ឍន៍បណ្ដាញទូរគមនាគមន៍អក្ខរៈលេខឆ្នាំ 1998-1999 ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានបើកសេវាបំរើការជួលជាវបរិបថអក្ខរៈលេខមានចំណុះល្បឿន និងប្រសិទ្ធិភាពខ្ពស់សំរាប់ភ្ជាប់គមនាគមន៍ពត៌មានគ្រប់ប្រភេទក្នុងទីក្រុង-ទីរួមខេត្ត និងរយៈផ្លូវឆ្ងាយ "ព្រំប្រទល់ប្រទេសថៃឡង់ត៍-ភ្នំពេញ-ព្រំប្រទល់ប្រទេសវៀតណាម" តាមបណ្ដាញកាប្លិ៍ *OPTIC* ។

សេវានឹងបានត្រូវផ្ដត់ផ្គង់តាមរយៈនៃកិច្ចព្រមព្រៀងជូនបណ្ដាក្រុមហ៊ុនការីបណ្ដាញទូរគមនាគមន៍ *(Network Operators)* និងអតិថិជនដែលមានអាជ្ញាប័ណ្ណបំរើសាធារណៈ តាមអត្ថន័យ និងលក្ខ័ណ្ឌដូចខាងក្រោម ៖

**១. អត្ថន័យ :**

១-១- បណ្ដាញកាប្លិ៍ *OPTIC* មានទម្រង់ជាបណ្ដាញមួយ ឬច្រើនកំណាត់ ***(Segments)*** តាមការសន្ទត់គិតពី "ចំណុចចុងទៅចំណុចចុង: ***End to End"*** តាមបណ្ដោយផ្លូវជាតិលេខ ៥ និងផ្លូវជាតិលេខ ១ ។

១.២- ការប្រើប្រាស់បណ្ដាញកាប្លិ៍ *OPTIC* ឬការភ្ជាប់បន្តបណ្ដាញ ***(Interconnection)*** គឺការតប្រតំបណ្ដាញផ្សេងៗ ***(Interface)*** ដោយភ្ជាប់ចូល ឬភ្ជាប់ចេញ នឹងបានត្រូវធានាអំពីអន្តរៈភាពប្រតិបត្តិការសេវា ***(Interoperability)*** ។

**២. ចំណុចភ្ជាប់បន្តបណ្ដាញ *(Interconnection Point)* :**

២.១- ចំណុចភ្ជាប់បន្ត គឺ " ស្ថានីយ៍ក្បាលបណ្ដាញ " ស្ថិតនៅមជ្ឈមណ្ឌលអង្គរ មហាវិថីសម្ដេចព្រះសីហនុ ក្រុងភ្នំពេញ និង "ចំណុចបណ្ដាញ" នៅតាមបណ្ដាស្ថានីយ៍នៅប៉ោយប៉ែត ទីរួមខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កំពង់ចម្លងអ្នកលឿង ទីរួមខេត្តស្វាយរៀង និងស្ថានីយ៍បាវិត ។ ចំណុចទាំងនោះអាចជាចំណុចបន្តចូល ***(Originating Point)*** ឬបន្តចេញ ***(Terminating Point)*** ។

២.២- ចំណុចទាំងនោះសោតក៏អាចបានត្រូវតពន្ធាតច្ងាយ (ពីមជ្ឈមណ្ឌលអង្គរនិងស្ថានីយ៍ដូចពោលខាងលើ)ដោយប្រើបណ្តាញក្រុងមានស្រាប់ ។

២.៣- ការភ្ជាប់បន្តចំណុចចូល ឬចំណុចចេញរវាងទីតាំងរបស់អ្នកប្រើប្រាស់ គឺការស្ពាបនាខ្សែ ឬបរិបថតប្រតំ *(Junction or Interface)* ក្នុងបន្ទុករបស់អ្នកប្រើប្រាស់ ឬដោយការផ្តល់ជាវដោយខ្សែកទៀត ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :.........៧៤.........បទ....ប្រក....

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ មិនា ឆ្នាំ 2002

# ប្រកាស

## ស្តីអំពីសេវាស្ថាបនាការ ថែទាំទូរស័ព្ទ ទូរសារ និងទូរពុម្ព ក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង

## រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា.
- បានឃើញ ព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០-០៧-៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦. ប្រកាសឱ្យប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ០៥អនក្រ ចុះថ្ងៃទី ០៥ ខែមិនា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ ៦៦អនក្រ.បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ សេចក្តីសំរេចលេខ ១៥៤សសរ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីថានានុក្រមគ្រប់គ្រងតម្លៃ.
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការផែនការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចុះថ្ងៃទី 04 ខែ មិនា ឆ្នាំ 2002 ស្តីអំពីសេវាទូរគមនាគមន៍សំរាប់ឆ្នាំ 2002 ដែលរៀបចំស្នើឡើងដោយក្រុមការងារដំណាងអង្គភាពជំនាញ.

## ស ំ រេ ច

**ប្រការ ១** : កំណត់តម្លៃស្លាបនាការ ថែទាំទូរស័ព្ទ ទូរសារ និងទូរពុម្ព សំរាប់តំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង ដូចមានចែងក្នុងតារាងភ្ជាប់មកជាមួយនេះ ។

**ប្រការ ២** : បណ្ដាញ សំភារៈស្លាបនា និងបរិធានទូរស័ព្ទ ជាបន្ទុករ៉ាប់រង និងជាកម្មសិទ្ធិរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ ៣** : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤** : ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកតាមតួនាទី ភារៈកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ។

**ប្រការ ៥** : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រ ដ្ឋ ម ន្ត្រី

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួង ផែនការ
- ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាពត៌មាន"
- ដូចប្រការ ៤
  "ដើម្បីអនុវត្តន៍"
- ឯកសារ-កាលប្បវត្តិ.

ប្រកាសលេខ ................ បទ.ប្រក/ .......... មិនា ឆ្នាំ 2002 ទំព័រ: 1/3

# តារាងថ្លៃសេវា
## ស្ថាបនាការ ថែទាំទូរស័ព្ទ ទូរសារ ទូរពុម្ព
## ក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង
## អនុវត្តចាប់ពីថ្ងៃទី 01 ខែ មេសា ឆ្នាំ 2002

| ក- ទូរស័ព្ទ ទូរសារ | I- តំបន់ក្រុងភ្នំពេញ | II- តំបន់ខេត្ត-ក្រុង |
|---|---|---|
| **១- ស្ថាបនាការទូរស័ព្ទ ទូរសារ** | | |
| ១.១- ស្ថាបនា-ភ្ជាប់បណ្តាញថ្មី | | |
| គិតទាំងបរិធាន និងសំភារៈ ........................ | 60$/គ្រឿង | 30$/គ្រឿង |
| ១.២- ប្តូរប្រព័ន្ធ ឬបណ្តាញ (Change Over) ....... | 30$/គ្រឿង | 15$/គ្រឿង |
| ១.៣- តម្លើបរិធានភ្ជាប់បំបែក (Parallel)(1) .......... | 25$/គ្រឿង | 15$/គ្រឿង |
| ១.៤- តម្លើងម៉ាស៊ីនទូរសារ(ម៉ាស៊ីនឯកជន)............ | 10$/គ្រឿង | 10$/គ្រឿង |
| ១.៥- ផ្ទេរទីកន្លែង (ក្នុងអាគារ) ........................ | 10$/គ្រឿង | 10$/គ្រឿង |
| ១.៦- ផ្ទេរអាស័យដ្ឋាន .............................. | 30$/គ្រឿង | 15$/គ្រឿង |
| **២- ការផ្តល់លេខទូរស័ព្ទ** (2)(4)(6) | | |
| ២.១- ផ្ទេរកម្មសិទ្ធិ "កាត់ឈ្មោះ" ...................... | 30$/លេខ | 15$/លេខ |
| ២.២- ផ្តល់លេខទូរស័ព្ទប្រភេទ "Reversed Signal" | 30$/លេខ | 30$/លេខ |
| ២.៣- ផ្តល់លេខទូរស័ព្ទប្រភេទ "Hunting Group" | 20$/លេខ | 20$/លេខ |
| ២.៤- ប្តូរលេខទូរស័ព្ទ ....................... | 30$/លេខ | 20$/លេខ |
| **៣- ប្រាក់ធានាតំកល់ទុកសំរាប់ការប្រើប្រាស់ទូរស័ព្ទ ទូរសារ (បង់មួយ)**(3) | | |
| ៣.១- សេវាក្នុងប្រទេស (DDD) ............................ | គ្មាន | គ្មាន |
| ៣.២- សេវាអន្តរជាតិ (IDD) .................. | 150$/លេខ | 100$/លេខ |

**៤- ការស្ថាបនាប្រើប្រាស់បណ្តោះអាសន្ន រយៈពី (៣)ខែខ្លីបំផុត : តំលៃសរុប :**

៤.១- អនុវត្តតម្លៃត្រង់ចំណុច ១.១ ស្មើ 50ភាគរយ.

៤.២- តម្លៃសេវាផ្សេងទៀតបើមានដូចត្រង់ចំណុច ១.៣, ២.២, ២.៣ ស្មើ 50ភាគរយ.

៤.៣- នឹងប្រាក់ធានាត្រង់ចំណុច ៣ ខាងលើ ។

ប្រកាសលេខ ................ បទ.ប្រក/ .......... មិនា ឆ្នាំ 2002 ទំព័រ: 2/3

ខ. **ទូរពុម្ព** (TELEX) (5) : **ការស្ថាបនាភ្ជាប់ប្តូរមណ្ឌលនៅក្រុងហុងកុង** :

១. ***តំបន់ក្រុងភ្នំពេញ***

១.១- ស្ថាបនាការទូរពុម្ព (4W) តម្លៃម៉ៅផ្តាច់ (ម៉ាស៊ីនឯកជន) ................ 280$/គ្រឿង

១.២- តម្លើងម៉ាស៊ីនទូរពុម្ព (ម៉ាស៊ីនឯកជន) ................................................ 30$/គ្រឿង

២. ***តំបន់ខេត្ត-ក្រុង*** អនុវត្តតំលៃដោយសារណាការ (Quotations) តាមខេត្ត-ក្រុងនិមួយៗ

២.១- តំលៃបរិបថចំណុះ 2.4Kbps (4W)

២.២- តំលៃម៉ៅផ្តាច់ក្នុងក្រុង (ម៉ាស៊ីនឯកជន) ................................................ 280$/គ្រឿង

២.៣- តម្លើងម៉ាស៊ីនទូរពុម្ព (ម៉ាស៊ីនឯកជន)

៣. ***ប្រាក់ធានាតំកល់ទុកសំរាប់ការប្រើប្រាស់ទូរពុម្ព (បង់មួយ)*** (3) ............ 150$/គ្រឿង

| គ. **ថ្លៃជួលសេវាប្រចាំខែ** | **តំបន់ក្រុងភ្នំពេញ** | **តំបន់ខេត្ត-ក្រុង** |
|---|---|---|
| ១. **ការប្រើប្រាស់ទូរស័ព្ទ-ទូរសារ** | | |
| ១.១- ជួលជាវនិងថែទាំបណ្តាញ | 7$/លេខ | 4$/លេខ |
| ១.២- បរិធានភ្ជាប់បំបែក | 2$/លេខ | 2$/លេខ |
| ១.៣- លេខទូរស័ព្ទប្រភេទ "Reversed signal " | 3$/លេខ | 3$/លេខ |
| ២. **ការប្រើប្រាស់ទូរពុម្ព** | | |
| ២.១- ជួលជាវនិងថែទាំបណ្តាញក្រៅប្រទេស | 34$/លេខ | |
| ២.២- ជួលជាវនិងថែទាំបណ្តាញក្នុងក្រុង | 20$/លេខ | |
| ២.៣- ជួលជាវនិងថែទាំបណ្តាញក្នុងប្រទេស .......... | 28$/លេខ | |

៣. **ការផ្អាកប្រើប្រាស់បណ្តោះអាសន្ន សេវាទូរស័ព្ទនិងសេវាទូរពុម្ព**

៣.១- អនុញ្ញាតិការផ្អាកបណ្តោះអាសន្នត្រឹមរយៈ3(បី)ខែ គិតថ្លៃ 50% នៃថ្លៃជួលជាវប្រចាំខែ ។

៣.២- ការបង់ថ្លៃជួលជាវសេវាដែលបានប្រើប្រាស់មិនពេញខែ ត្រូវបានគិតតាមចំនួនថ្ងៃប្រើប្រាស់ក្នុងតំលៃ ១/៣០ភាគមួយថ្ងៃនៃថ្លៃជួលជាវប្រចាំខែ ។

៤. **ការផ្តល់វិក័យប័ត្រលំអិតលើការប្រើប្រាស់សេវា** (7)

៤.១- តំបន់ក្រុងភ្នំពេញ : វិក័យប័ត្រលំអិតលើសន្ទនាការទូរស័ព្ទប្រចាំខែ .................. 2$/ច្បាប់

៤.២- តំបន់ខេត្ត-ក្រុង : វិក័យប័ត្រលំអិតលើសន្ទនាទូរស័ព្ទប្រចាំខែ អាចផ្តល់ជូនដោយឥតគិតថ្លៃ បើមានសំណើផ្ទាល់របស់អតិថិជន ។

ប្រកាសលេខ ................ បទ.ប្រក/ .......... មិនា ឆ្នាំ 2002 ទំព័រ: 3/3

**លក្ខខណ្ឌនៃការផ្គត់ផ្គង់សេវា :**

(1)- ការស្នាបនា-តម្លើងបរិធានភ្ជាប់បំបែក (Parallel) ត្រូវបានអនុញ្ញាតតាមលក្ខណៈបច្ចេកទេសបាន មួយគ្រឿងក្នុងអាគារតែមួយ សំភារៈផ្គត់ផ្គង់ដោយក្រសួង ។

(2)- លេខទូរស័ព្ទត្រូវបានផ្គត់ផ្គង់ជូនជាកម្មសិទ្ធឯកជន ពុំអាចបំរើសាធារណៈដោយគ្មានច្បាប់អនុញ្ញាត ។

(3)- ប្រាក់ធានាតំកល់ទុកត្រូវបានបង់ក្នុងគ្រាស្នាបនាការ និងត្រូវតែបង្វែរជូនអតិថិជនវិញ ល្គិកណាបាន សុំបញ្ឈប់ការប្រើប្រាស់សេវាជាស្ថាពរ និងបានធ្វើការទូទាត់ថ្លៃសេវាគ្រប់ចំនួន ។

(4)- ភ្នាក់ងារមានច្បាប់លក់លេខទូរស័ព្ទនៅរាជធានីភ្នំពេញ អាចគិតយកថ្លៃ 30ដុល្លា (30$) និងនៅ ខេត្ត មួយគ្រឿង 10ដុល្លា (10$) បន្ថែមលើថ្លៃស្នាបនាការគ្រាដំបូង (Installation Fees) ដែលរដ្ឋកំណត់ សំរាប់ការងារសិក្សាទីផ្សារ និងផ្សព្វផ្សាយពាណិជ្ជកម្ម ។

(5)- ការស្នាបនាប្រើប្រាស់សេវាទូរពុម្ព (Telex) ជាបណ្តោះអាសន្នពុំត្រូវបានអនុញ្ញាត ។

(6)- ការផ្លាស់ប្តូរលេខទូរស័ព្ទ ត្រូវធ្វើការទូទាត់បំណុលថ្លៃសេវាជាមុន ។

(7)- វិក័យប័ត្រប្រើប្រាស់សេវាត្រូវបានចេញជូនរៀងរាល់ដំណាច់ខែ នៃប្រតិទិន មានទំរង់ជាតារាងសរុប លើប្រភេទសន្ទនាការ ។ អតិថិជនអាចសុំអោយផ្តល់វិក័យប័ត្រតាមករណីពិសេសដោយត្រូវបង់ថ្លៃ បន្ថែម ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :.........៨១០.........បទ.ប្រក

រាជធានី-ភ្នំពេញ ថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ២០០២

# ប្រ កា ស

## ស្តីអំពីការគ្រប់គ្រងបរិក្ខាវិទ្យុគមនាគមន៍និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី០៥-០៣-៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីអំពីប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦/អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី១១-១២-៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ



កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ទូរស័ព្ទ: (៨៥៥) ២៣-៧២៨៩១០/៤២៦៥១០

- យោងស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការផែនការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ នាថ្ងៃទី០៤ ខែមិនា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងបរិក្ខាវិទ្យុគមនាគមន៍ និង ការកែប្រែតម្លៃប្រើប្រាស់រលកអាកាសវិទ្យុ សំរាប់ឆ្នាំ២០០២ ដែលរៀបចំស្នើឡើងដោយក្រុមការងារ តំណាងអង្គភាពជំនាញ ។

## សំរេច

ប្រការ១: កំនត់គោលការប្រើប្រាស់សេវាបរិក្ខាវិទ្យុគមនាគមន៍ ដូចមានឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៣ភ្ជាប់នឹង សេចក្តីប្រកាសនេះ ។

ប្រការ២: ប្រកាសស្តីអំពីការគ្រប់គ្រងបរិក្ខាវិទ្យុគមនាគមន៍និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ លេខ០៨១ បទ.ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០១ និងរួមទាំងប្រកាសទាំងឡាយណាដែលមានពីមុន ហើយមានន័យផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៣: ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួងប.ទ ត្រូវទទួលបន្ទុកអនុវត្តតាមតួនាទី ភារកិច្ចនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៤: ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រដ្ឋមន្ត្រី

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាពត៌មាន "
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ .............បទ.ប្រក ចុះថ្ងៃទី ..........ខែ មិនា ឆ្នាំ ២០០២

## ឧបសម្ព័ន្ធទី១
## ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ
## ចាប់អនុវត្តន៍ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០២

**១- វិទ្យុប្រភេទ MF** — រៀល

ក/វិទ្យុប្រភេទ MF ចល័ត

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បថនភ័ណ្ឌមួយគៀងៗ ១០,០០០
- ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើងលើនាវា ៣០,០០០
- ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើងលើដីគោក ២៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ថបនភ័ណ្ឌមួយគ្រឿងៗ
  ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ៧០,០០០+៣,០០០X+៧,០០០Y

ខ/វិទ្យុប្រភេទ MF អចល័ត

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ថបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ២៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ថបនភ័ណ្ឌមួយគ្រឿងៗ
  ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ៧០,០០០+២,០០០X+៧,០០០Y

**២- វិទ្យុប្រភេទ HF** — រៀល

*សំគាល់: ចំពោះស្ថានទូតក្នុងការទាក់ទងផ្ទាល់ជាមួយប្រទេសរបស់ខ្លួន ត្រូវបានអនុគ្រោះមិនគិតតម្លៃអាជ្ញាប័ណ្ណ ។*

ក/វិទ្យុប្រភេទ HF ចល័ត

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បថនភ័ណ្ឌមួយគៀងៗ ១០,០០០
- ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើងលើនាវា ៣០,០០០
- ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើងលើដីគោក ២៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ថបនភ័ណ្ឌមួយគ្រឿងៗ
  ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ៧០,០០០+៣,០០០X+៧,០០០Y

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ .............បទ.ប្រក ចុះថ្ងៃទី ..........ខែ មិនា ឆ្នាំ ២០០២

ខ/វិទ្យុប្រភេទ HF អចល័ត

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ២៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ
  ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ៧០,០០០+១,៥០០X+៧,០០០Y

៣- **វិទ្យុប្រភេទ VHF** រៀល

ក/វិទ្យុប្រភេទ VHF ចល័តទូទាំងក្នុងផ្ទៃប្រទេស

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង :
  ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (walkie talkie) ១០,០០០
  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០
  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភណ្ឌ័មួយគ្រឿងៗ
  ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ៣០,០០០+១,៨០០X+៨០០Y

ខ/វិទ្យុប្រភេទ VHF ចល័តក្នុងខេត្ត/ក្រុង

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង :
  ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (walkie talkie) ១០,០០០
  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០
  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភណ្ឌ័មួយគ្រឿងៗ
  ចំពោះអានុភាព X watt និង បន្ទារប្រេកង Y KHz ៣០,០០០+១,៥០០X+៨០០Y

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ .............បទ.ប្រក ចុះថ្ងៃទី ..........ខែ មិនា ឆ្នាំ ២០០២

គ/វិទ្យុប្រភេទ VHF អចល័ត

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ

  ចំពោះអានុភាព X watt និង បន្ទារប្រេក្វង់ Y KHz ៣០,០០០+១,០០០X+៨០០Y

៤- **វិទ្យុប្រភេទ UHF** រៀល

ក/វិទ្យុប្រភេទ UHF ចល័តទូទាំងក្នុងផ្ទៃប្រទេស (PTT : Push To Talk)

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង :

  ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (walkie talkie) ១០,០០០

  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០

  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភណ្ឌ័មួយគ្រឿងៗ

  ចំពោះអានុភាព X watt និង បន្ទារប្រេក្វង់ Y KHz ៣០,០០០+១,៥០០X+៨០០Y

ខ/វិទ្យុប្រភេទ UHF ចល័តក្នុងខេត្ត/ក្រុង

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង :

  ចំពោះវិទ្យុទាក់ទងតូចៗកាន់ជាប់នឹងដៃ (walkie talkie) ១០,០០០

  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើនាវា ២០,០០០

  ចំពោះវិទ្យុទាក់ទងធម្មតាពុំមែនកាន់ជាប់នឹងដៃនៅលើដី ១៥,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភណ្ឌ័មួយគ្រឿងៗ

  ចំពោះអានុភាព X watt និង បន្ទារប្រេក្វង់ Y KHz ៣០,០០០+១,៣០០X+៨០០Y

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ .............បទ.ប្រក ចុះថ្ងៃទី .........ខែ មិនា ឆ្នាំ ២០០២

គ/វិទ្យុប្រភេទ UHF អចល័ត (PPT : Push To Talk)

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ១០,០០០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ១០,០០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភណ្ឌ័មួយគ្រឿងៗ

  ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ៣០,០០០+១,០០០X+៨០០Y

៥- **វិទ្យុប្រភេទ TLMRS ឬផេជិង ឬប្រព័ន្ធទូរស័ព្ទចល័ត ឬទូរស័ព្ទអចល័តឥតប្រើខ្សែ** $

*<u>សំគាល់</u> ចំពោះបរិក្ខាតូចៗ ឬ កាន់ជាប់នឹងដៃពុំចាំបាច់មានអាជ្ញាប័ណ្ណទេ ។*

- ការទទួលពិនិត្យពាក្យសុំដំណើរការ Base Station ៥០
- ការពិនិត្យឋបនភ័ណ្ឌសំរាប់ Base Station ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ដំណើរការនៃប្រព័ន្ធទូទាំងប្រទេស

  ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ១០០ + ៣០X + ២.៥Y

៦- **វិទ្យុប្រភេទ Wireless Access** $

ក/ ករណីសំរាប់ ISP

- ការទទួលពិនិត្យពាក្យសុំដំណើរការ Base Station ៥០
- ការពិនិត្យឋបនភ័ណ្ឌសំរាប់ Base Station ១០០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ដំណើរការនៃប្រព័ន្ធទូទាំងប្រទេស

  ចំពោះបន្ទារប្រេកង់ Y KHz ៥០០ + ០.២Y

  ( ចំពោះ Subscriber របស់ ISP ពុំចាំបាច់មានអាជ្ញាប័ណ្ណទេ )

ខ/ ករណីធម្មតា

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ៣០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភណ្ឌ័មួយគ្រឿងៗ

  តូចជាង រឺ ស្មើ 1,024Kbps ៥០០

  ធំជាង 1,024Kbps ៦០០

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ .............បទ.ប្រក ចុះថ្ងៃទី ..........ខែ មិនា ឆ្នាំ ២០០២

**៧-** **វិទ្យុគ្រប់ប្រភេទជា** MICRO-WAVE $

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ឋបនភ័ណ្ឌមួយគ្រឿងៗ ៣០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ឋបនភ័ណ្ឌមួយគ្រឿងៗ :

ក/ **បង់ហ្វ្រេកង់** ពី១.៥GHz ទៅ ៦GHz

| | | | | |
|---|---|---|---|---|
| **ចាប់ពី** | 2Mbps | តែតូចជាង | 8Mbps | ៥០០ |
| **ចាប់ពី** | 8Mbps | តែតូចជាង | 34Mbps | ៦០០ |
| **ចាប់ពី** | 34Mbps | តែតូចជាង | 140Mbps | ៨០០ |
| **លើសពី** | 140Mbps | លើងទៅ | | ១,០០០ |

ខ/ **បង់ហ្វ្រេកង់** ពី៧ GHz ទៅ ១៥GHz

| | | | | |
|---|---|---|---|---|
| ចាប់ពី | 2Mbps | តែតូចជាង | 8Mbps | ៤៥០ |
| ចាប់ពី | 8Mbps | តែតូចជាង | 34Mbps | ៥៥០ |
| ចាប់ពី | 34Mbps | តែតូចជាង | 140Mbps | ៧០០ |
| លើសពី | 140Mbps | លើងទៅ | | ៨៥០ |

គ/ **បង់ហ្វ្រេកង់** លើសពី១៥ GHz លើងទៅ

| | | | | |
|---|---|---|---|---|
| ចាប់ពី | 2Mbps | តែតូចជាង | 8Mbps | ៤០០ |
| ចាប់ពី | 8Mbps | តែតូចជាង | 34Mbps | ៥០០ |
| ចាប់ពី | 34Mbps | តែតូចជាង | 140Mbps | ៦០០ |
| លើសពី | 140Mbps | លើងទៅ | | ៧០០ |

**៨-** **បរិក្ខាទំនាក់ទំនងអន្តរជាតិ (ក្នុងករណីមានការអនុញ្ញាតិពិសេស)** $

ក/ វិទ្យុទាក់ទងអន្តរជាតិ (PTT)

- ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ ១០
- ការពិនិត្យឋបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ២០
- តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់វិទ្យុមួយគ្រឿង ២០ + ០.៨X + ២Y

ខ/ VSAT សំរាប់សំលេង / ទិន្នលេខ

| | |
|---|---|
| -ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ | ៥០ |
| -ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ១០០ |
| -តម្លៃសួយសារប្រចាំខែ | ៣,០០០ |
| -តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សម្រាប់ស្ថានីយ៍មួយគ្រឿង | ៤,០០០ |

គ/ VSAT សំរាប់បញ្ជូនរូបភាពទូរទស្សន៍ (Non-preemptible)

| | |
|---|---|
| -ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ | ៥០ |
| -ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ១០០ |
| -តម្លៃអាជ្ញាប័ណ្ណប្រចាំថ្ងៃ សម្រាប់ស្ថានីយ៍មួយគ្រឿង | ៣,០០០ |

**៩- វិទ្យុផ្សាយសំលេង** $

| | |
|---|---|
| -ការទទួលពិនិត្យពាក្យសុំបើកស្ថានីយនិមួយៗ | ៣០ |
| -ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ៥០ |

ក/តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ AM ; SW

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ១០០ + 0.0៥X + ២០Y

ខ/តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំលើវិទ្យុប្រភេទ FM

ចំពោះអានុភាព X watt និង បន្ទារប្រេកង់ Y KHz ១០០ + 0.0៥X + ២Y

**១០- ទូរទស្សន៍** $

| | |
|---|---|
| - ការទទួលពិនិត្យពាក្យសុំបើកស្ថានីយនិមួយៗ | ៣០ |
| -ការពិនិត្យថបនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង | ៥០ |

ក/តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ VHF

ចំពោះអានុភាព X watt និង បន្ទារប្រេកង Y KHz ១០០ + 0.0៥X + 0.0៥Y

ខ/តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ UHF

ចំពោះអានុភាព X watt និង បន្ទារប្រេកង; Y KHz ១០០ + 0.0៥X + 0.0៤Y

គ/តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំពោះទូរទស្សន៍ប្រភេទ MMDS

ចំពោះអានុភាព X watt និង បន្ទារប្រេកង; Y KHz ១០០ + 0.0៥X + 0.0៣Y

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ .............បទ.ប្រក ចុះថ្ងៃទី ..........ខែ មិនា ឆ្នាំ ២០០២

**១១-** **វិទ្យុអាម៉ាទ័រ** $

-ការទទួលពិនិត្យពាក្យសុំប្រើប្រាស់ ៥

-ការពិនិត្យបថនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ១០

-តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ២៥

**១២-** **អ៊ិនម៉ាសាត INMARSAT** $

*ក/អ៊ិនម៉ាសាតគ្រប់ប្រភេទចល័តឬអចល័ត ឬ តាំងជាប់នៅលើនាវា*

១-ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ ៣០

២-ការពិនិត្យបថនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ១០០

៣-តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ២០០

៤-តម្លៃប្រើប្រាស់ស្មើនឹងតម្លៃរបស់ស្ថានីយ៍អ៊ិនម៉ាសាតលើដី +១៥%

៥-ប្រាក់កក់សំរាប់ទូទាត់តម្លៃនៃការប្រើប្រាស់អ៊ិនម៉ាសាត១គ្រឿង ១.០០០

ចំពោះអ៊ិនម៉ាសាតតាំងជាប់នៅលើនាវា អតិថិជនអាចមិនជ្រើសរើសយកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ធ្វើជាអាជ្ញាធរទូទាត់ ( Accounting Authority ) សំរាប់ទូទាត់តម្លៃជាមួយស្ថានីយ៍អ៊ិនម៉ាសាតលើដី។ ក្នុងករណីនេះចំនុច ៤និង៥មិនត្រូវគិតទេ ។

ខ/ចំពោះអ៊ិនម៉ាសាតគ្រប់ប្រភេទ ដែលចុះឈ្មោះនៅបរទេសហើយនាំចូល

មកប្រើប្រាស់នៅលើទឹកដីក្នុងព្រះរាជាណាចក្រកម្ពុជា $

-ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខានិមួយៗ ៣០

-ការពិនិត្យបថនភ័ណ្ឌមួយគ្រឿងៗ មុនពេលតំលើង ៥០

-តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ៤០០

**១៣-** **ល័ក្ខខ័ណ្ឌនៃការផ្គត់ផ្គង់សេវា**

*ក្រសួងប.ទជំរុញការអភិវឌ្ឍន៍និងការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ដែលសមស្របតាមលក្ខណៈបច្ចេកទេស។ ក្នុងករណីដែលប្រព័ន្ធទូរគមនាគមន៍ពុំទាន់មាន ក្រសួងប.ទបានអនុញ្ញាតិឱ្យមានការប្រើប្រាស់វិទ្យុទូរគមនាគមន៍ ហើយបានកំណត់តម្លៃទាបសំរាប់ប្រេកង់នោះ។ប៉ុន្តែក្នុងករណីដែលប្រព័ន្ធបណ្តាញទូរគមនាគមន៍មានរួចហើយ តម្លៃប្រេកង់សេវានោះនឹងមានកំរិតមកជា*

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ .............បទ.ប្រក ចុះថ្ងៃទី .........ខែ មិនា ឆ្នាំ ២០០២

ធម្មតាវិញ។ ដូច្នេះហើយតម្លៃប្រេកង់ក្នុងតារាងតម្លៃនេះអាចមានកំរិតខ្ពស់ ឬទាប ទៅតាមករណីនិមួយៗ។ ក្នុងករណីដែលអាចធ្វើឱ្យប៉ះពាល់ដល់ សេវានៃបណ្ដាញទូរគមនាគមន៍ខ្លាំងពេក ក្រសួងប.ទអាចមិនអនុញ្ញាត្តិឱ្យប្រើប្រាស់ប្រព័ន្ធវិទ្យុគមនាគមន៍នោះ។

១៣.១ ចំពោះអង្គការមនុស្សធម៌អន្តរជាតិ ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលមានកិច្ចព្រមព្រៀងក្របខ័ណ្ឌក្នុងការអនុគ្រោះពន្ធទូទៅជាមួយព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានអនុគ្រោះ៧០% នៃតម្លៃធម្មតាសំរាប់តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ។

១៣.២ ចំពោះ Two-Way Radios បន្ទាត់ប្រេកង់នៃវិទ្យុមានពីរផ្នែកគឺផ្សាយនិងទទួល។ ក្នុងករណីនេះ ការគិតតម្លៃប្រេកង់ គឺគិតតែមួយផ្នែកដែលជាបរិក្ខាផ្សាយ ។

១៣.៣ អានុភាពផ្សាយគិតតាមអានុភាពអតិបរិមានៃបរិក្ខារ ។

១៣.៤ រយៈពេលកំណត់នៃអាជ្ញាប័ណ្ណមានមួយឆមាស ឬ មួយឆ្នាំ។ ក្នុងករណីអាជ្ញាប័ណ្ណមានរយៈពេលមួយឆមាស តម្លៃអាជ្ញាប័ណ្ណនោះស្មើនឹងពាក់កណ្ដាលនៃតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ។

១៣.៥ ការសុំប្រើប្រាស់បន្តដោយគ្មានប្រការណាមួយប្រែប្រួលនៅក្នុងអាជ្ញាប័ណ្ណចាស់ គឺត្រូវគិតតែតម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់អាជ្ញាប័ណ្ណថ្មី ។

១៣.៦ អ្នកកោសលុប ឬ ក្លែងបន្លំដោយប្រការណាមួយនៅលើអាជ្ញាប័ណ្ណ ត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ .............បទ.ប្រក ចុះថ្ងៃទី ..........ខែ មិនា ឆ្នាំ២០០២

**ឧបសម្ព័ន្ធទី២**

**ច្បាប់ទទួលស្គាល់បរិធានវិទ្យុគមនាគមន៍**

**ចាប់អនុវត្តន៍ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០២**

| (Type Approval) | $ |
|---|---|
| ទូរស័ព្ទធម្មតា | ១.០០០ |
| ទូរស័ព្ទចល័ត | ២.០០០ |
| ផេជិង | ១.០០០ |
| ទូរសារ | ២.០០០ |
| បមាណី (PABX) | ២.០០០ |
| បរិក្ខាវិទ្យុ | ១.៥០០ |
| បរិធានវិទ្យុទូរគមនាគមន៍ដទៃផ្សេងទៀត | ១.៥០០ |
| ច្បាប់បង្កើតភ្នាក់ងារនាំចូលបរិធានវិទ្យុទូរគមនាគមន៍ | ១.០០០ |
| តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ភ្នាក់ងារនាំចូល ឬលក់ ឬជួសជុលបរិធានវិទ្យុទូរគមនាគមន៍ | ១០០ |

ឧបសម្ព័ន្ធភ្ជាប់ប្រកាសលេខ .............បទ.ប្រក ចុះថ្ងៃទី .........ខែ មិនា ឆ្នាំ ២០០២

## ឧបសម្ព័ន្ធទី៣

## ការផាកពិន័យ

## ចាប់អនុវត្តន៍ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០២

*សំគាល់ :* ប្រាក់ពិន័យពុំមែនជាប្រាក់សំរាប់ទូទាត់តម្លៃអាជ្ញាប័ណ្ណទេ ។

១ ការប្រើប្រាស់បរិក្ខាវិទ្យុគមនាគមន៍មួយគ្រឿងទោះចល័តក្តីអចល័តក្តី ហើយគ្មានអាជ្ញាប័ណ្ណ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខានោះគុណនឹង០.៥ ។

២ ការផ្លាស់ប្តូររលកអាកាសវិទ្យុ ដោយគ្មានការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខានោះគុណនឹង០.៤ ។

៣ ការផ្លាស់ប្តូរឋបនភ័ណ្ឌវិទ្យុគមនាគមន៍ ឬទីតាំងឋបនភ័ណ្ឌវិទ្យុគមនាគមន៍ដោយគ្មាន ការអនុញ្ញាតពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំនៃបរិក្ខានោះគុណនឹង០.៣ ។

៤ ការប្រើប្រាស់អាជ្ញាប័ណ្ណហួសពេលកំណត់ ប្រាក់ពិន័យស្មើនឹង តំលៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ នៃបរិក្ខានោះគុណនឹង០.២ ។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ៨១ បទ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ 2002

## ប្រកាស

### ស្តីអំពីថ្លៃសេវាទូរគមនាគមន៍ និងរូបភាពទូរទស្សន៍ ប្រើប្រាស់ក្នុងប្រទេស និងអន្តរជាតិ

### រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/1198/72 ចុះថ្ងៃទី 30 វិច្ឆិកា 1998. ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា.
- បានឃើញ ព្រះរាជក្រមលេខ 02នស/94 ចុះថ្ងៃទី 20 កក្កដា 1994 ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញ ព្រះរាជក្រមលេខ នស.រកម.0196.20 ចុះថ្ងៃទី 24 មករា 1996 ប្រកាសឱ្យប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ 05អនក្រ ចុះថ្ងៃទី 05 មិនា 1987 របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ អនុក្រឹត្យលេខ 66អនក្រ ចុះថ្ងៃទី 22 តុលា 1997 ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍.
- បានឃើញ សេចក្តីសំរេចលេខ 154សសរ ចុះថ្ងៃទី 11 ធ្នូ 1991 របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ.
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការផែនការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចុះថ្ងៃទី 04 ខែ មិនា ឆ្នាំ 2002 ស្តីអំពីតម្លៃសេវាទូរគមនាគមន៍ សំរាប់ឆ្នាំ 2002 ដែលរៀបចំស្នើឡើងដោយក្រុមការងារដំណាងអង្គភាពជំនាញ.

## សំរេច

**ប្រការ ១** : កំណត់ថ្លៃសេវាទូរគមនាគមន៍ និងរូបភាពទូរទស្សន៍ សំរាប់ការប្រើប្រាស់ក្នុងប្រទេស និងអន្តរជាតិ ដូចមានចែងក្នុងតារាងថ្លៃសេវាភ្ជាប់មកជាមួយនេះ ។

**ប្រការ ២** : ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្ត តាមតួនាទី ភារៈកិច្ចនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៤** : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

**កន្លែងទទួលៈ**

- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច

" ដើម្បីជូនជ្រាបជាព័ត៌មាន "

- ដូចប្រការ 3

" ដើម្បីអនុវត្តន៍ "

- ឯកសារ-កាលប្បវត្តិ.

ប្រកាសលេខ: ...................... បខ-ប្រក/ ........ មិនា ឆ្នាំ 2002 ទំព័រ : 1/5

**តារាងថ្លៃសេវា**

**សម្រាប់សន្ទនាការទូរស័ព្ទ គមនាគមន៍ពត៌មាន**

**និងរូបភាពទូរគមនាគមន៍ក្នុងប្រទេស និងអន្តរជាតិ**

**សេវា និងបណ្ដាញរបស់រដ្ឋ**

**តម្លៃអនុវត្តចាប់ពីថ្ងៃទី 01 ខែ មេសា ឆ្នាំ 2002 វេលាសូន្យម៉ោងតទៅ**

## I- សេវា និងបណ្ដាញដែនដី :

### ១. ទូរស័ព្ទក្នុងប្រទេស :

**១.១. សន្ទនាទូរស័ព្ទ DDD : គិតជា " សេនសហរដ្ឋ មួយនាទី "**

| សេវារដ្ឋ / បណ្ដាញទូរស័ព្ទ | ម៉ោងសេវា | ថ្លៃសន្ទនាការទូរស័ព្ទ (DDD) | | | |
|---|---|---|---|---|---|
| | | ក្នុងក្រុង/តំបន់ | | ទូរស័ព្ទផ្លូវឆ្ងាយ | |
| | | ភ្នំពេញ | ខេត្ត | ក្នុងភូមិភាគ | ក្រៅភូមិភាគ |
| ក. ហៅក្នុងប្រព័ន្ធរដ្ឋ<br>+អចល័ត (Fixed) :<br>D.2.4,7 និង 8 | 06 ម៉ោ00-18 ម៉ោ00 | 1c | | 8C | 10C |
| | 18 ម៉ោ00-06 ម៉ោ00 | | | 5C | |
| ខ. ហៅឆ្លងប្រព័ន្ធក្រុមហ៊ុន<br>+អចល័ត (Fixed)<br>D.3 និង D.9 | 06 ម៉ោ00-18 ម៉ោ00 | 5C | | 10C | |
| | 18 ម៉ោ00-06 ម៉ោ00 | | | | |
| គ. ហៅឆ្លងប្រព័ន្ធក្រុមហ៊ុន<br>+ចល័ត (Mobile)<br>C.011, 012, 015, 016, 018 | 06 ម៉ោ00-18 ម៉ោ00 | 12C | | | |
| | 18 ម៉ោ00-06 ម៉ោ00 | | | | |

**១.២. សន្ទនាតាមរយៈទូរស័ព្ទការី** (OPERATION ASSISTED) : ថ្លៃអប្បបរិមាស្មើ 3នាទីដំបូង និងបន្ថែម 3នាទី ជាបន្តបន្ទាប់.

**២-សន្ទនាទូរស័ព្ទអន្តរជាតិ** IDD : គិតជា " ដុល្លារសហរដ្ឋ មួយនាទី "

| **និសដៅ** | **តម្លៃធម្មតា** | **ថ្ងៃសៅរ៍និងអាទិត្យ** (ពី 00ម៉00- 23ម៉59) |
|---|---|---|
| ២.១- ប្រទេសឡាវ វៀតណាម និងថៃឡង់ | 1.35 | 1.05 |
| ២.២- ប្រទេសដទៃទៀតក្នុងទ្វីបអាស៊ី | 1.44 | 1.15 |
| ២.៣- បណ្តាប្រទេសក្នុងទ្វីបដទៃទៀត | 1.62 | 1.30 |

២៤- សន្ទនាតាមរយៈទូរស័ព្ទការី (OPERATOR ASSISTED) : គិតថ្លៃអប្បបរិមាស្មើ 3នាទីដំបូងនៃតម្លៃធម្មតា រួចបន្ថែមមួយនាទីជាបន្តបន្ទាប់.

**៣. ទូរសារសាធារណៈ** :

**៣.១. ការទទួល និងចែកដល់អាសយដ្ឋាន** : គិតជាប្រាក់ " រៀល "

តម្លៃអនុវត្តលើបន្ទុកម្ចាស់អ្នកទទួលសារ បើអ្នកផ្ញើរពុំបានបង់ថ្លៃជាមុន.

៣.១.១- ការទទួលគិតជាទំព័រ .............. 100៛ មួយទំព័រ

៣.១.២- ការចែកដល់អាស័យដ្ឋានក្នុងក្រុងគិតជាច្បាប់ 1.000៛ មួយច្បាប់

ប្រកាសលេខ: ...................... បទ-ប្រក/ ........ មិនា ឆ្នាំ 2002 ទំព័រ : 2/5

**៣.២. ការបញ្ជូនទូរសារសាធារណៈក្នុងប្រទេស** : គិតជា " សេនសហរដ្ឋ មួយនាទី "

| បណ្តាញទូរស័ព្ទ \ សេវារដ្ឋ | ម៉ោងសេវា | ថ្លៃបញ្ជូនទូរសារសាធារណៈ | | | |
|---|---|---|---|---|---|
| | | ក្នុងក្រុង/តំបន់ | | ទូរសារផ្លូវឆ្ងាយ | |
| | | ភ្នំពេញ | ខេត្ត | ក្នុងភូមិភាគ | ក្រៅភូមិភាគ |
| **ក. ហៅក្នុងប្រព័ន្ធរដ្ឋ** +អចល័ត (Fixed) : D.2,4,7 និង 8 | 06ម៉ោ00-18ម៉ោ00 | 10c | | 18c | 20c |
| | 18ម៉ោ00-06ម៉ោ00 | | | 15c | |
| **ខ. ហៅក្នុងប្រព័ន្ធក្រុមហ៊ុន** +អចល័ត ឥតខ្សែ : D.3 និង D.9 | 06ម៉ោ00-18ម៉ោ00 | 15c | | 20c | |
| | 18ម៉ោ00-06ម៉ោ00 | | | | |
| **គ. ហៅក្នុងប្រព័ន្ធក្រុមហ៊ុន** +ចល័ត (Mobile) : C.011, 012, 015, 016, 018 | 06ម៉ោ00-18ម៉ោ00 | 22c | | | |
| | 18ម៉ោ00-06ម៉ោ00 | | | | |

**កំណត់សំគាល់** : ត្រូវបន្ថែមថ្លៃសេវាទទួល និងចែកដល់អាស័យដ្ឋាន បើមានសំណើ.

**៣.៣. ការបញ្ជូនទូរសារអន្តរជាតិ** : គិតជា " ដុល្លាសហរដ្ឋ មួយនាទី "

| **ទិសដៅ** | **តម្លៃធម្មតា** | **ថ្ងៃសៅរ៍និងអាទិត្យ** (ពី 00ម៉ោ00- 23ម៉ោ59) |
|---|---|---|
| ៣.៣.១- ប្រទេសឡាវ វៀតណាម និងថៃឡង់ | 1.55 | 1.25 |
| ៣.៣.២- ប្រទេសដទៃទៀតក្នុងទ្វីបអាស៊ី | 1.64 | 1.35 |
| ៣.៣.៣- បណ្តាប្រទេសក្នុងទ្វីបដទៃទៀត | 1.82 | 1.50 |

**៤. ទូរពុម្ព** :

| **ទិសដៅ** | **ទូរពុម្ព** | **ទូរពុម្ពសាធារណៈ** | **ទូរលេខ** |
|---|---|---|---|
| | (គិតជាដុល្លាសហរដ្ឋ/នាទី) | | (គិតជាដុល្លាសហរដ្ឋ/ពាក្យ) |
| ៤.១- ក្នុងប្រទេស | 0.30 | 0.34 | 0.04 |
| ៤.២- ក្រុងហុងកុង | 1.90 | 2.10 | 0.25 |
| ៤.៣- ប្រទេសឡាវ វៀតណាម និងថៃឡង់ | 2.20 | 2.50 | 0.28 |
| ៤.៤- ប្រទេសដទៃទៀតក្នុងទ្វីបអាស៊ី | 2.35 | 2.56 | 0.30 |
| ៤.៥- ប្រទេសក្នុងទ្វីបដទៃទៀត | 2.50 | 2.70 | 0.32 |

ប្រកាសលេខ: ..................... បទ-ប្រក/ ........ មីនា ឆ្នាំ 2002 ទំព័រ : 3/5

<u>**កំណត់សំគាល់**</u> : ១- ទូរលេខមួយច្បាប់គិតអប្បបរិមា ស្មើ 10ពាក្យ មានតម្លៃ និងអាចិកាលទទួល និងចែកជូនដល់អាស័យដ្ឋាន.

២- ទូរពុម្ពសាធារណៈក្នុងប្រទេសត្រូវគិតបន្ថែមថ្ងៃសេវាទទួល និងចែកដល់អាស័យដ្ឋាន ដូចក្នុងចំណុច ៤ ខាងក្រោម ។

**៥.** <u>**ការទទួល និងចែកសារទូរពុម្ពសាធារណៈ**</u> : គិតជាប្រាក់ " រៀល "

តម្លៃអនុវត្តលើបន្ទុកម្ចាស់អ្នកទទួលសារ បើអ្នកផ្ញើរពុំបានបង់ថ្លៃជាមុន.

៥.១- ការទទួលគិតជាទំព័រ .............. 150៛ មួយទំព័រ

៥.២- ការចែកដល់អាស័យដ្ឋានក្នុងក្រុង ............. 1.000៛ មួយឡូវ

**៦.** <u>**សេវាវិទ្យុទូរស័ព្ទក្នុងប្រទេស**</u> : សន្ទនាការគិតជា " សេវាសហរដ្ឋ " 3នាទីដំបូងនិងនាទីបន្តបន្ទាប់ ។

៦.១- សន្ទនានៅផ្ទាល់តាមស្ថានីយ៍វិទ្យុ : គ្រប់ការិយាល័យប្រៃសណីយ៍និងទូរគមនាគមន៍

សន្ទនារវាងខេត្ត-ក្រុង ................................40c/3នាទី

៦.២- សន្ទនាពាក់កណ្តាលស្វ័យប្រវត្តិ ហៅលេខ code " 094 "

សន្ទនារវាងខេត្ត-ក្រុង ................................50c/3នាទី

៦.៣- លិខិតអញ្ជើញជួបសន្ទនា (គិតជាប្រាក់រៀល) ..........1.000៛/ឡូវ

**៧.** <u>**សេវា**</u> <u>E-mail</u> <u>**សាធារណៈ**</u> តាមរយៈ Internet " Camnet "

៧.១- ការប្រើប្រាស់ Internet : 1$/10 នាទី និងគិត 10នាទីបន្ថែមជាបន្តបន្ទាប់.

៧.២- ការបញ្ជូន E-mail : 1$/Message (បើលើសពី១០នាទី គិតយកតាម ៧.១)

៧.៣- ការប្រើប្រាស់ Computer

៧.៣.១- សរសេរអត្ថបទ 1$/ម៉ោង

៧.៣.២- Printer 500៛/ទំព័រ

**៨.** <u>**សេវាបញ្ជូនរូបភាពទូរទស្សន៍អន្តរជាតិ:**</u> តាមរយៈប្រព័ន្ធ Intelsat

ថ្លៃគិតត្រឹមពាក់កណ្តាលផ្លូវពីស្ថានីយ៍ Studio ដល់ផ្កាយអវកាស :

៨.១- រយៈពេលអប្បបរមា 10នាទីដំបូង ........................300$/10នាទី

៨.២- មួយនាទីជាបន្តបន្ទាប់ .................................. 20$/នាទី

៨.៣- ការផ្ញើយផ្លូងសម្របសម្រួលបរិបថផ្កាយរណប (Space Segment) ជាបន្ទុកនៃស្ថានីយ៍ Studio ទទួល ( Receiving Station ) ជាអ្នករ៉ាប់រង ។

## II- **សេវាវិទ្យុផ្លូវសមុទ្រ** :

### ១. **តំបន់សេវាក្រុងព្រះសីហនុ និងផ្ទៃសមុទ្រខាងត្បូង**

#### ១.១. **សេវាស្ថានីយ៍ឆ្នេរ** "XUK" : ឥតបានគិតបញ្ចូលសេវាបណ្តាញក្នុងប្រទេស

| ប្រភេទសេវា | ថ្លៃសេវាតាមប្រភេទស្ថានីយ៍ | | កំណត់សម្គាល់ |
|---|---|---|---|
| | HF / MF | VHF | |
| ១.១.១- វិទ្យុទូរលេខ: Radio telegrams | 4c/ពាក្យ | | |
| ១.១.២- លិខិតវិទ្យុឆ្នេរ: Radio maritime letters | គិតបន្ថែមថ្លៃសេវាប្រៃសណីយ៍ | | - វិទ្យុទូរលេខបញ្ជូនបន្តតាមប្រៃសណីយ៍ |
| ១.១.៣- វិទ្យុទូរស័ព្ទ: Radio telephone | 1.65$/នាទី | 20c/នាទី | |
| ១.១.៤- វិទ្យុទូរពុម្ព : Radiotelex | 1.82$/នាទី | | |
| ១.១.៥- ទូរលេខវិទ្យុទូរពុម្ព : Radiotelexogram | គិតបន្ថែមថ្លៃសេវាទូរពុម្ព | | - វិទ្យុទូរលេខបញ្ជូនបន្តតាមទូរពុម្ព |
| ១.១.៦- ការបញ្ជូន-ទទួលសារប្រកាសអាសន្ន ........................................ | | | តំលៃពិគ្រោះជាមួយស្ថាប័នពាក់ព័ន្ធ |
| ១.១.៧- ការឆ្លើយឆ្លងពត៌មានឧតុនិយម ........................................ | | | |

**១.២. ការភ្ជាប់បន្តសេវាក្នុងប្រទេស** : សេវាពាក់កណ្តាលស្វ័យប្រវត្តិគិតអប្បបរមា 3នាទី និងមួយនាទីបន្ថែមជាបន្តបន្ទាប់ ស្ថានីយ៍នាវាដែលសុំសេវា ជាអ្នកបង់ថ្លៃសេវា ។

| **បន្តសេវា:** | **តំលៃត្រូវគិត** : |
|---|---|
| ១.២.១- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅអន្តរជាតិ | សេវាអន្តរជាតិ+សេវាស្ថានីយ៍ឆ្នេរ |
| ១.២.២- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅស្ថានីយ៍នាវា | សេវាស្ថានីយ៍ឆ្នេរ × 2 ដង |
| ១.២.៣- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅបណ្តាញក្នុងប្រទេស | សេវាស្ថានីយ៍ឆ្នេរ+សេវាក្នុងប្រទេស |

១.២.៤- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅស្ថានីយ៍នាវាតាមស្ថានីយ៍ឆ្នេរប្រទេសដទៃ : សេវាអន្តរជាតិ+សេវាស្ថានីយ៍ឆ្នេរបរទេស + ស្ថានីយ៍ឆ្នេរ

**១.៣. លក្ខខណ្ឌសំរាប់ស្ថានីយ៍នាវា** :

១.៣.១- ស្ថានីយ៍នាវាអាចគិតយកថ្លៃសេវាបន្ថែមលើថ្លៃខាងលើសំរាប់ចរន្តសេវាសាធារណៈដោយ មានការផ្សព្វផ្សាយជាមុន ។

១.៣.២- ស្ថានីយ៍នាវាដែលពុំមានអាជ្ញាប័ណ្ណប្រើប្រាស់ស្ថានីយ៍វិទ្យុ និងពុំមានអាជ្ញាធរទូទាត់គណនីប្រើប្រាស់សេវា ពុំមានសិទ្ធិសុំសេវាស្ថានីយ៍ឆ្នេរ ។

១.៣.៣- ស្ថានីយ៍ឆ្នេរត្រូវធ្វើការទូទាត់គណនីសេវារបស់ស្ថានីយ៍នាវាដោយផ្ទាល់ជាមួយអាជ្ញាធរទូទាត់គណនី (Accounting Authority) រៀងរាល់ដំណាច់ត្រីមាសប្រតិទិនមួយៗ ។

ប្រកាសលេខ: ...................... បទ-ប្រក/ ........ មិនា ឆ្នាំ 2002 ទំព័រ : 5/5

**១.៤. បន្ទុកសេវាផ្ទាល់ទៅខាងស្ថានីយ៍ខ្មែរ** (Liaison Direct) :

១.៤.១- រវាងស្ថានីយ៍ខ្មែរក្នុងប្រទេស : គ្មាន

១.៤.២- រវាងស្ថានីយ៍ខ្មែរអន្តរជាតិ : អនុវត្តន៍កិច្ចព្រមព្រៀងអន្តរជាតិ.

**២. គមនាគមន៍ពត៌មានតាមរយៈ** : INMARSAT ជាប្រភេទសេវាអន្តរជាតិ

**២.១. សន្ទនាការចេញពីបណ្ដាញក្នុងប្រទេស** (IDD) ................... 3$/នាទី

**២.២. សន្ទនាការចេញពីស្ថានីយ៍នាវា** : តម្លៃសរុប

២.២.១- សេវាស្ថានីយ៍ខ្មែរ

២.២.២- សេវាក្នុងប្រទេស

២.២.៣- សេវា INMARSAT

**កំណត់សំគាល់** : សន្ទនាការ INMARSAT អាចភ្ជាប់តាមរយៈមាត់ច្រកអន្តរជាតិដោយប្រើ Codes :

១. Atlantic Ocean Region " AOR - West " : 871

២. Pacific Ocean Region " POR " : 872

៣. Indian Ocean Region " IOR " : 873

៤. និង Atlantic Ocean Region " AOR - East " : 874

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៙៙ ❖ ៙៙

**ក្រសួងអប់រំយុវជន និង កីឡា**

**លេខ : ៧៦៣ អយក.ប្រក**

# ប្រកាស

ស្តីពីការបើកសាលាបឋមសិក្សាឯកជន ខ្មែរ-ចិន **ពួយ ហួ**

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-បានពិនិត្យលិខិតស្នើសុំរបស់លោក **ជឹម ហុង** ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ដោយចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ពោធិសាត់ លេខ ៤១៣ អយក.ពស ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ។
-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១** :-បើកសាលាបឋមសិក្សា ខ្មែរ-ចិន **ពួយ ហួ** ដែលមានទីតាំងស្ថិតនៅភូមិ ស្ពានថ្ម សង្កាត់ រលាប ស្រុក សំពៅមាស ខេត្ត ពោធិសាត់ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :-សាលាបឋមសិក្សា ខ្មែរ-ចិន **ពួយ ហួ** ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ពោធិសាត់ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ៣** :-លោក **ជឹម ហុង** ត្រូវដឹកនាំគ្រប់គ្រង ចាត់តាំងគណៈគ្រប់គ្រងសាលារៀន និង គ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ព្រមទាំងអនុវត្តអោយបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងអប់រំយុវជន និង កីឡា ។

**ប្រការ៤** :-នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម នឹង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ពោធិសាត់ ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក សំពៅមាស នាយកសាលាបឋមសិក្សា ខ្មែរ-ចិន **ពួយ ហួ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០២

**ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម-សិទ្ធី**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
 " ដើម្បីជូនជ្រាបជាពត៌មាន "
- សាលាខេត្ត ពោធិសាត់ " ជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ ឯកសារ នា -ប.ប